# ជីវិតម៉ែ

620.

បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE



ដោយ

**វីរិយបណ្ឌិតោ ភិក្ខុ ចាំង ខាត់**

**សម្តេចព្រះពោធិវង្ស ហួត តាត**

អគ្គាធិការពុទ្ធិកសិក្សា

អធិបតីក្រុមជំនុំព្រះត្រៃបិដក ពុទ្ធសាសនបណ្ឌិត្យ

ពិនិត្យផ្ទៀងផ្ទាត់

៦២០.
៣០

ព.ស ២៥៤២ គ.ស ១៩៩៩

# ជីវិតម៉ែ

ដោយ

## វីរិយបណ្ឌិតោ ភិក្ខុ ប៉ាង ខាត់

## សម្តេចព្រះពោធិវ័ង្ស ហួត តាត

អគ្គាធិការពុទ្ធិកសិក្សា

អធិបតីក្រុមជំនុំព្រះត្រៃបិដក ពុទ្ធសាសនបណ្ឌិត្យ

ពិនិត្យផ្ទៀងផ្ទាត់

LIBRARY BUDDHIST INSTITUTE
៦៧៣៨/០២

ព.ស ២៥៤២ គ.ស ១៩៩៩

# សូមឧទ្ទិសជូនញោមទាំងពីរ

ឧបាសក ប៉ាង

ឧបាសិកា អុង

អ្នកកំណើតជាបុព្វាចារ្យ

អ្នកឱ្យជីវិតថ្មី ជីវិតកូនថ្មីនេះ ជាជីវិតញោម

កូននឹកមិនភ្លេច

កុសលដែលកើតពីធម្មយាត្រានមស្ការ

ពុទ្ធស្ថានប្រទេសឥណ្ឌានេះ កូនលើក

ជូន

ញោមទុកជាបណ្ណាការដ៏វិសេស

សូមញោមបានសំរេចៈ

សម្បត្តិមនុស្ស

សម្បត្តិទេវតា

សម្បត្តិព្រះនិព្វាន

កុំបីខានឡ

ក្រុងដែល្ហី, ថ្ងៃទី៣ តុលា ១៩៦៤

ប៉ាង ខាត់

# ស្នាដៃនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង

**ពុទ្ធសាសនបណ្ឌិត្យ** និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**

ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត

ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ

សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់

**អង្គការរីស្សូ កូសី-កៃ  វិទ្យាស្ថានបើកទូលាយ**

**ការុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា**

ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage.  This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

www.budinst.gov.kh        www.elibraryofcambodia.org

# បទដើម

ជាបឋមខ្ញុំសូមណែនាំអស់លោកអ្នកជាទីគោរពមេត្រីឱ្យបានជ្រាបនូវវត្ថុបំណងនៃការបោះពុម្ពសៀវភៅ ជីវិតម៉ែ នេះសាជាថ្មី។

ការបោះពុម្ពសាជាថ្មីនៃសៀវភៅនេះ បានធ្វើឡើងដោយមូលនិធិកម្ពុជា ដែលជាអង្គការមួយបង្កើតឡើងដើម្បីស្រាវជ្រាវ សិក្សាផ្នែកអក្សរសាស្ត្រនិងថែរក្សាអរិយធម៌ សិល្បៈ និងវប្បធម៌ខ្មែរ។

ក្នុងការស្រាវជ្រាវសិក្សាផ្នែកអក្សរសាស្ត្រ មូលនិធិកម្ពុជាបានបង្កើតនូវកម្មវិធីគណិតូបករណ៍ ( Computer Program ) មួយ សំរាប់ប្រើភាសាខ្មែរក្នុងការសរសេរ និង គិតលេខ។

ការរកឃើញកម្មវិធីនេះ គឺជាដំណាក់កាលនៃការវិវត្តន៍មួយដ៏សំខាន់សំរាប់ប្រវត្តិអក្សរសាស្ត្រខ្មែរយើង បន្ទាប់ពីការបង្កើតអង្គុលីលេខខ្មែរ ដោយលោកសាស្ត្រាចារ្យ កេង វ៉ាន់សាក់ មក ។ ឯការជុសខាត់សំអាតកម្មវិធីនេះ ដើម្បីកែតួអង្គអក្សរឬស្រះឱ្យបានល្អប្រសើរ ជាងនេះទៅទៀតនៅតែប្រព្រឹត្តទៅរាល់ថ្ងៃ ដោយការព្យាយាមជាទីបំផុត។

ជាការសាកល្បងលើកទី១ ក្នុងការបោះពុម្ពអក្សរខ្មែរដោយប្រើរបៀបគណិតូបករណ៍ ខ្ញុំបានលើកយករឿង ជីវិតម៉ែ ដែលជាស្នាព្រះហស្ថនៃព្រះមហាវីរិយបណ្ឌិតោ ប៉ាង ខាត់ យកមកបោះពុម្ពចែកជូនបង

ប្អូនយើងអានសាជាថ្មីដោយយល់ថា សៀវភៅនេះមានតម្លៃដ៏ខ្ពស់ប្រសើរសំរាប់បុត្រធីតាទូទៅក្នុងលោកនេះ។

ថ្វីបើព្រះបណ្ឌិតនិពន្ធរឿងនេះច្រើនរើសយកឧទាហរណ៍ដែលមានការទាក់ទងជាមួយវប្បធម៌ខ្មែរសុទ្ធសាធ តែសន្តានចិត្តមាតាទូទៅគ្រប់ជាតិសាសន៍ក្នុងទ្វីបលោកនេះមានដូចគ្នាតែមួយគឺ " ម៉ែ " ដែលព្រះមហាវីរិយបណ្ឌិតោ ប៊ាង ខាត់ បានធ្វើអត្ថាធិប្បាយដ៏ពិរោះក្បោះក្បាយជាទីបំផុតក្នុងសៀវភៅដ៏តូចនេះ ។

" ម៉ែ ម៉ាក់ មាតា " អ្នកជាប្រភពដើមនៃសេចក្តីស្រឡាញ់ នៃការថ្នាក់ថ្នម និងជាប្រភពនៃសភាវៈទន់ភ្លន់ ផ្អែមល្ហែមផង ព្រមទាំងជាអ្នកដែលទទួលនូវការលំបាកនឿយហត់ជាងគេក្នុងគ្រួសារ ។

ម៉ែតែងប្រាថ្នាយ៉ាងជ្រាលជ្រៅឱ្យបុត្រធីតាបានទៅជាកូនល្អប្រសើរជាទីបំផុត ហើយម៉ែស្រឡាញ់បុត្រធីតាជាជាងទ្រព្យសម្បត្តិដ៏មានតម្លៃនានាទាំងអស់ក្នុងលោកនេះ ។

បើបុត្រធីតារាល់រូបគោរពតាមឱវាទ និងគន្លងធម៌ដែលមាតាបានថែងទុកមកនោះ ពិភពលោកយើងនេះ ប្រហែលនឹងពុំអាចទៅជាពិភពមួយដែលពោរពេញទៅដោយអំពើបាបកម្ម មានការកាប់សម្លាប់គ្នា ជាដើមឡើយ។ គួរឱ្យស្តាយជាពន់ពេកណាស់ ចំពោះកំហុសនៃកូនអកត្តញ្ញូ

មួយជំពូកនេះ ។

ខ្ញុំពុំអាចជ្រើសរកពាក្យពេជន៍ដ៏មានតម្លៃណាមួយ យកមកថ្លែងអំណរព្រះគុណចំពោះថ្វីព្រះហស្ដដ៏ឆ្នើមនេះ និងក្នុងការសុំអនុញ្ញាតបោះពុម្ពសៀវភៅ " ជីវិតម៉ែ " នេះសាជាថ្មីបានឡើយ ។ សូមព្រះបណ្ឌិតមេត្តាអភ័យទោសដល់ខ្ញុំព្រះករុណាដែលពុំអាចសុំការអនុញ្ញាតផ្ទាល់ពីព្រះអង្គបាន ។

ម្យ៉ាងទៀតក្នុងការបោះពុម្ពនេះ ខ្ញុំបានរក្សាលំនាំដើមទាំងអស់ ទាំងអត្ថបទ ទាំងអក្ខរាវិរុទ្ធ ព្រមទាំងរូបភាពទាំងប៉ុន្មានដែលបោះពុម្ពក្នុងឆ្នាំ១៩៦៤ ដោយលោកមហា ឡាយ គ្រី ។

បើមានការខុសឆ្គងដោយប្រការណាមួយ ខ្ញុំសូមអភ័យទោសដោយគោរពពីសំណាក់លោកអ្នកអានជាទីមេត្រី ។

ជាអវសានកថានេះ ខ្ញុំសូមប្រសិទ្ធិពរគ្រប់ប្រការចំពោះព្រះអង្គប៉ាង ខាត់ ព្រមទាំងគ្រួសារញាតិមិត្តរបស់ព្រះអង្គទាំងអស់ និងសូមឱ្យស្នាព្រះហស្ដដ៏ពិសេសនេះក្លាយទៅជាឱសថទិព្វដ៏ពូកែមួយ ដែលអាចព្យាបាលចិត្តបាបនៃកូនអកត្តញ្ញូទាំងឡាយក្នុងលោក ឱ្យនឹកឃើញគុណអ្នកម្ដាយដ៏ធ្ងន់នេះ និងសូមឱ្យកូនមួយជំពូកទៀតនឹកឃើញដល់គុណ " មាតាធំ " គឺមាតុភូមិកម្ពុជាជាទីស្រឡាញ់ និងជាទីស្ថានកំណើតនៃ

យើងរាល់គ្នា ។ សូមឱ្យមាតុភូមិដែលធ្លាប់តែផ្តល់នូវសេចក្តីសុខក្សេមក្សាន្តដល់យើងជាបុត្រធីតានេះ បានរួចចាកផុតពីក្រញាំដៃនៃពួកជនអកត្តញ្ញូមួយក្រុម ដែលកំពុងតែធ្វើទារុណកម្មដល់ "មាតាធំ" រាល់ថ្ងៃនេះ ។

ក្រុង Austin ថ្ងៃទី ១៥ ខែ ធ្នូ គ.ស ១៩៨៦
តំណាងគណៈកម្មការវប្បធម៌នៃមូលនិធិកម្ពុជា
កុល ផេង

# បទនាំ

តាំងពី គ.ស ១៩៥៩ ដល់ ១៩៦២ សៀវភៅ " ជីវិតម៉ែ " បានបោះពុម្ពផ្សាយចំនួនជិតពីរម៉ឺនក្បាលហើយ ដោយលោកសប្បុរស អ្នកមានសទ្ធា សុំបោះពុម្ពចែកជាទាន ។

ពេលនេះសេចក្តីត្រូវការនៃសាធារណជនកាន់តែច្រើនឡើងៗ លោកចាងហ្វាងរោងពុម្ព ឧដុងរស្មី បានចូលមកសុំយកទៅបោះផ្សាយ ដើម្បីបំរើបំណងសាធារណជន ។ ខ្ញុំបានសរសេរសុំសេចក្តីអនុញ្ញាតពីព្រះមហាវីរិយបណ្ឌិតោ ដែលកំពុងបំពេញបេសកកម្មបំរើព្រះពុទ្ធសាសនានៅប្រទេសឥណ្ឌា ។ ព្រះអ ង្គលោកមានព្រះទ័យប្រកបដោយមេត្តាករុណា បានសរសេរតបតវិញដូចមាននៅទំព័រដើមនេះស្រាប់ ។

ដើម្បីបំពេញបំណងជនទាំងឡាយ ក្នុងការអានសៀវភៅនេះ ខ្ញុំបានកែក្រឡឱ្យមានសម្រស់ល្អ និងបន្ថែមរូបភាពជាតំណាងកិច្ចការម៉ែឪ ដែលបានបំរើប្រយោជន៍កូនគ្រប់កាលៈទេសៈ ។

ព្រះមហាវីរិបណ្ឌិតោ បានអនុញ្ញាតពិសេសឱ្យខ្ញុំធ្វើការនេះដោយព្រះអង្គលោកមិនបានពិនិត្យព្រោះនៅឆ្ងាយ ។ ការនេះ ទោះទាស់ខុសបន្តិចបន្តួចក៏គ្រាន់បើជាជាងមិនធ្វើដែរ ឱ្យតែធ្វើដោយចិត្តបរិសុទ្ធ ។

ខ្ញុំមានសេចក្តីសប្បាយចិត្តណាស់ ចំពោះសេចក្តីអនុញ្ញាតពិសេស

នេះ ប៉ុន្តែខ្ញុំនៅមានសេចក្តីព្រួយបារម្ភខ្លាំងអំពីការនិមន្តធ្វើធម្មយាត្រានមស្ការពុទ្ធស្ថានផ្សេងៗនៅឥណ្ឌានៃព្រះអង្គលោក ព្រោះប្រទេសឥណ្ឌាមានអាកាសធាតុកាចសាហាវប្លែកអស្ចារ្យ លំបាករស់នៅជាទីបំផុតផង ព្រោះអាហារ ប្រពៃណី ចរិតលក្ខណៈ និងអាការៈនៃមនុស្សប្លែកពីខ្មែរយើងផង។ ប៉ុន្តែខ្ញុំជឿជាក់ថា បុណ្យ និង បាប តែងអន្ទោលតាមប្រាណប្រៀបដូចស្រមោល ឬថា សាបព្រោះពូជបែបណា បានផលផ្លែផ្កាបែបនោះ ។

ព្រះមហាវីរិយបណ្ឌិតោ បានសាបព្រោះពូជកុសលពូជសម្មាទិដ្ឋិច្រើនប្រការណាស់ តែនៅក្នុងពេលនេះខ្ញុំយកតែកុសលជាស្នាព្រហស្តព្រះអង្គលោកខ្លះៗដែលខ្ញុំនឹកឃើញមករៀបរាប់តទៅនេះ :

១- ពុទ្ធជីវប្រវត្តិ

២- ពុទ្ធជីវប្រវត្តិតាមទស្សនៈអ្នកអស្តង្គត

៣- ស្រីហិតោបទេស ៤ភាគ

៤- រឿងបញ្ចតន្ត្រៈ

៥- ប្រវត្តិពុទ្ធសាសនាប្រទេសខ្មែរ

៦- ប្រវត្តិពុទ្ធសាសនា (សម្រាប់សមណនិស្សិតពុទ្ធិកមហាវិទ្យាល័យព្រះសីហនុ )

៧- ជីវិតមនុស្ស

៨. មគ្គទេ្ទសក៍នគរ ២ភាគ
៩. អត្ថសម្មាបណិធិកថា
១០. វិរិយកថា
១១. កោសជ្ជកថា
១២. បរាភវកថា
១៣. សុចរិតកថា
១៤. សទ្ធាកថា
១៥. វឌ្ឍនភាពនៃការសិក្សាសម័យបុរាណនៃប្រទេសខ្មែរ
១៦. សិលាចារឹកពុទ្ធសាសនានៅប្រទេសខ្មែរ
១៧. កាយកតាសតិកម្មដ្ឋាន
១៨. ទេវទូត
១៩. ឧបនីយតិសូត្រ
២០. គិលានុបដ្ឋានកថា
២១. មនុស្សចង់បានអ្វី ?
២២. ការបួស
២៣. ជុំវិញការចេះដឹង
២៤. ពុទ្ធសាសនា និង វិទ្យាសាស្រ្ត
២៥. បុណ្យគឺអ្វី ?

២៦. ការត្រាស់ដឹងនៃព្រះសម្ពុទ្ធ

២៧. សំវេគធម៌

២៨.ក្សត្រធម៌

២៩. ជីវិតម៉ែ

៣០. សាសនាឥស្លាមសង្ខេប

៣១. វប្បធម៌សំស្រ្កឹតពីបូរាណ

៣២. ព្រះពុទ្ធសាសនាគឺអ្វី ?

៣៣. គួរសាងអនុស្សាវរីយ៍ព្រះមហាវិមលធម្មថោងឬទេ ?

៣៤. ចូរបបួលគ្នាសាបព្រោះពូជសម្មាទិដ្ឋិ

៣៥. Le Buddhi au Cambodge

សូមផលនៃកុសលកម្មនេះក្លាយទៅជាគ្រឿងគ្រោះអាចការពារព្រះវិរិយបណ្ឌិតោ ប៉ាង ខាត់ ឱ្យបានសម្រេចឥដ្ឋមនុញ្ញផលវិបុលសុខជរាបនិវត្តន៍មកប្រទេសខ្មែរវិញ ។

វត្តឧណ្ណាលោម, ថ្ងៃទី២០ តុលា ១៩៦៤

កុសលានុរក្ខិភិក្ខុ ឡាយ គ្រី ហៅ គូ

និស្សិតពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជក្រុងភ្នំពេញ

# អារម្ភកថា

ក្នុងឱកាសបុណ្យឆ្លងជន្មាយុគម្រប់ ៩០ឆ្នាំ នៃញោមស្រីរបស់ខ្ញុំ ខ្ញុំបានសរសេរសៀវភៅធម៌មួយបោះពុម្ពសំរាប់ចែកជាធម្មទានយកកុសលជូនញោមស្រីខ្ញុំ ដើម្បីឱ្យញោមស្រីបានកុសលច្រើន ។

កាលមុនសរសេរសៀវភៅនេះ ខ្ញុំគិតថាគួរសរសេរធម៌អ្វី? គិតៗទៅឃើញថា គួរសរសេរពីជីវិតម៉ែឪ ដែលបង្កើតកូនមក ហើយចិញ្ចឹមដោយព្រហ្មវិហារធម៌ ចង់ឱ្យកូនរស់រានមានជីវិតតាមភ្នែកយើងមើលឃើញ ហើយឱ្យសៀវភៅនេះឈ្មោះថា" ជីវិតម៉ែ " ទុកជាប្រយោជន៍ឱ្យកូនរាល់រូបពិចារណាមើលឱ្យឃើញគុណម៉ែឪ តែស្តាយណាស់ដែលខ្ញុំរករឿងម៉ែឪយកមកនិយាយឱ្យសព្វគ្រប់ពុំបាន ព្រមទាំងសរសេរមិនដល់ទឹកចិត្តម៉ែឪគ្រប់រូបដែលតែងតែមានចំពោះកូនទៀត ។

ខ្ញុំសរសេររួចហើយ ខ្ញុំបានយកទៅប្រគេនជូនព្រះថេរៈច្រើនព្រះអង្គ និងអស់លោកច្រើនរូបឱ្យជួយពិនិត្យមើល ទីបំផុតខ្ញុំបានទៅសុំសេចក្តីអនុគ្រោះពីព្រះតេជគុណព្រះពោធិវង្ស សូមព្រះអង្គលោកជួយពិនិត្យមើលទៀត ព្រះអង្គលោកក៏មានមេត្តាសង្គ្រោះជួយកែតម្រឹមតម្រូវឱ្យទានដោយករុណា សូមគ្រេកអរចំពោះព្រះតេជគុណទុកនៅក្នុងទីនេះដោយគោរព ។

ប៉ាង ខាត់

# បទទីមួយ

## មាតាបិតាជាព្រះព្រហ្ម

ពុទ្ធភាសិត

ម៉ែឪ ជាព្រះរបស់កូន

ណ្ហើយ ! អត្ថគម្ពីរភាពទុកងារឱ្យអ្នកបរមត្ថទៅចុះ ក្នុងទីនេះយើងនិយាយងាយៗទៅតាមមើលឃើញ ទៅតាមឮ ទៅតាមដឹងតៗមក មិននិយាយទៅតាមជើងគម្ពីរសុទ្ធពេកទេ ។

សត្វមានមេបាវាបង្កើត មនុស្សមានម៉ែឪបង្កើត មិនមែនទេពតាណាមួយបង្កើតទេ ។

ដូច្នេះកូនពិតជាម៉ែឪ បង្កើត ដូចពុទ្ធភាសិតមួយបទថា " មិនដែលឃើញព្រាហ្មណ៍ណាមួយកើតមកពីមាត់ព្រហ្មទេ ឃើញតែកើតមកពីម៉ែឪ" ។

បុរសស្ត្រីគ្រប់រូបមុននឹងមានកូនក៏មិនឈ្មោះថាម៉ែឪ ឬហៅថាម៉ែឪពុំទាន់បានទេ.លុះគ្រាតែមានកូនហើយទើបបានមានបញ្ញត្តិថា" ម៉ែឪ"

ម៉ែឪ ជាឯកភាពតែមួយ កើតឡើងដោយការសម្ព័ន្ធ ជាធម៌ធម្មតាប្រក្រតី ជាធម៌ស័ក្តិសិទ្ធិរបស់កូន មានតម្លៃប៉ុនគ្នា មានទម្ងន់ប៉ុនគ្នា មានន័យដូចគ្នា តែអ្នកផងទាំងពួងច្រើនតែកំបាំងភ្នែកមើលមិនសូវឃើញថា



ព្រះពុទ្ធជាព្រះរបស់មនុស្សលោកទាំងអស់
ដូច្នេះក៏ជាព្រះរបស់កូនប្រុស កូនស្រីទាំងអស់គ្នាដែរ.

មានគុណភាពឬមានតម្លៃអ្វីប៉ុន្មានទេ គេច្រើនទុកដាក់ថាជារបស់ធម្មតាទៅវិញ។ អើ ! អ្វីមួយដែលស័ក្តិសិទ្ធិ ដែលមានតម្លៃ តែកាលណាត្រឡប់ទៅជាធម្មតាប្រក្រតីហើយ ច្រើនតែកំបាំងភ្នែកមើលមិនសូវឃើញទេ តែយើងត្រូវមូលចិត្តថា ការដែលពិតបើអាក្រក់នៅតែអាក្រក់ បើល្អនៅតែល្អឥតប្រែប្រួលសភាពពិតទៅជាប្រការដទៃឡើយ ។

មួយទៀតម៉ែឪតែងតែបង្កើតកូន មានកូនហើយតែងតែស្រឡាញ់កូន មានភារៈចិញ្ចឹមបីបមថ្នាក់ថ្នម ថែរក្សាទំនុកបំរុងអប់រំសង្គ្រោះកូនដែលខ្លួនកសាងឱ្យកើតឡើងទុកតពូជពង្សឱ្យបានឋិតថេរចីរកាលតវែងទៅ មិនមែនតែប៉ុណ្ណោះទេ ម៉ែឪ មានចិត្តប្រកបដោយព្រហ្មវិហារធម៌គឺ មេត្តា ករុណា មុទិតា ឧបេក្ខា ជាធម៌សម្រាប់ប្រោះព្រំកូនឱ្យជានិច្ចនិរន្តន៍ឱ្យបានសុខសប្បាយទៀត ។

ការចិញ្ចឹមកូនឱ្យរស់ ឱ្យសុខសប្បាយ ហើយឱ្យបានទៅជាមនុស្សល្អនេះជាភារៈធ្ងន់ណាស់ កម្រក្រៃលែង ម៉ែឪត្រូវព្យាយាមបំផុត ដោយកាយវាចា ដោយចិត្ត ដោយវិធីគ្រប់យ៉ាងតាមតែអាចធ្វើបាន ដើម្បីឱ្យកូនបានរស់ ហើយឱ្យកូនបានទៅជាមនុស្សល្អ។ បើយើងសួរថាកូនគឺអ្វី? កូនគឺមនុស្ស មនុស្សគឺមនុស្សលោក បើកូនមនុស្សលោក ហើយម៉ែឪមិនមែនត្រឹមតែម៉ែឪ របស់កូនទេគឺម៉ែឪ របស់លោក ព្រោះលោកមិនគឺអ្វីដទៃក្រៅពីមនុស្សនេះទេ ។ ការធ្វើឱ្យមនុស្សល្អ គឺការធ្វើឱ្យលោកល្អ

ឱ្យសុខចំរើនក្សេមក្សាន្ត ជាធម៌ប្រសើរក្រៃលែង ។ ហេតុនេះហើយបាន ជាលោកពោលថា មាតាបិតាជាបុព្វការីបុគ្គលមានគុណធ្ងន់ក្រៃលែង ធ្ងន់នឹងគណនាត្រារាប់ពុំបានឡើយ ។

ចំណែកកូនដែលបានទទួលឧបការៈពីម៉ែឪ ដែលបានជ្រកកោន ក្រោមម្លប់ម៉ែឪ ហើយបានរស់រានមានជីវិត បានសុខសប្បាយត្រជាក់ ត្រជុំក្សេមក្សាន្ត តែងបានឃើញច្បាស់នូវសុភមង្គលទាំងនេះនៅក្នុងចិត្ត នៃខ្លួន គួរតែបង្អោនចិត្តទៅរកម៉ែឪ គោរពម៉ែឪ ទុកម៉ែឪជាទេពតា ឬ ជាព្រះរបស់ខ្លួន ។ ពេលមានអាសន្នកូនតែងតែនឹកដល់ម៉ែឪ សំបូង សង្រួងសូមឱ្យគុណម៉ែឪ ជួយខ្លួន រីឯអំណាចព្រហ្មវិហារធម៌ក៏ស័ក្តិសិទ្ធិ ណាស់អាចជ្រាបចូលទៅមុតដល់ថ្លើមប្រមាត់ ធ្វើចិត្តកូនឱ្យធូរស្រាល ឱ្យ កក់ក្ដៅ ឱ្យដកដង្ហើមធូរស្រួល ហើយឱ្យរីករាយសប្បាយចិត្តហៅពេល ណារសាយចិត្តពេលនោះ ក្នុងពេលមានទុក្ខធំគ្រាន់តែហៅ ឬនឹកក្នុងចិត្ត ថា ម៉ែឪ ប៉ុណ្ណោះក៏ក្សាន្តចិត្តបានខ្លះដែរ ។ ដូច្នេះពាក្យថាម៉ែឪ នេះ ឃើញថាជានាមមានគុណ ភាពធំណាស់ ហាក់ដូចជានាមទេពតាដ៏ស័ក្តិ សិទ្ធិមួយដែរ ។ រីឯពាក្យនេះដោយគោរពកូនហៅថា មាតាបិតា ជនក ជននីដោយស្និទ្ធស្នាលកូនតែងហៅថា ម៉ែឪ ម្ដាយឪពុក ចា៎ ពុក ប៉ះ ម៉ះ ។ល។ បណ្ដាពាក្យទាំងនេះពាក្យដែលកូនចូលចិត្តហៅជានិច្ចកាល ច្រើន ហៅថាម៉ែឪ ។ ពាក្យនេះកូនហៅរាល់ពេលយប់ថ្ងៃហៅស្និទ្ធិមាត់

អស់ពីពោះពុង អស់ដួងចិត្ត ហៅឥតកោតញញើត ឥតធុញទ្រាន់ មិនចេះជិនណាយ ឮហើយពិរោះត្រចៀកមិនសង្កៀរត្រចៀកទេ ។ មានតែពាក្យម៉ែឪ នេះទេដែលកូនពេញចិត្តហៅ ហៅដដែលៗហៅរាល់ថ្ងៃ ហៅហើយហៅទៀត ហៅមិនមានពេលវេលាជិនណាយហៅរហូតទល់រលត់ខ្យល់ចេញចូល ។ ចំណែកម៉ែឪ ឮកូនហៅហើយក៏រីករាយសប្បាយចិត្តខ្លាំងណាស់ ។

ទីបំផុតជីវិតកូនជាជីវិតម៉ែឪ កូនរស់នៅដោយសារម៉ែឪ ម៉ែឪរស់នៅក៏រស់នៅដោយសារកូន ជីវិតម៉ែឪ និងជីវិតកូនមានការសម្ព័ន្ធគ្នាជិតជិតណាស់ សូម្បីតែកូនកំព្រាឥតម៉ែឪ ម៉ែឪស្លាប់ចោលទៅតាំងពីតូចមិនទាន់បានឃើញមុខម៉ែឪក៏ដឹងថាមានម៉ែឪ ហើយគិតថា ម៉ែឪគង់ស្រលាញ់ខ្លួនបីបមថ្នាក់ថ្នមចិញ្ចឹមថែរក្សា អប់រំសង្គ្រោះ យកចិត្តទុកដាក់នឹងខ្លួនដូចម៉ែឪ គេផងទាំងឡាយដោយហោចណាស់គិតថាពេលកើតទុក្ខបានម៉ែជួយសម្រាលលំហែទុក្ខពេលយំហៀរហូរទឹកភ្នែកបានម៉ែយកសំពត់ជូតទឹកភ្នែកឱ្យ បបោសអង្អែលលួងលោមឱ្យកូនដកដង្ហើមបានស្រួល ឱ្យកូនរីករាយសប្បាយចិត្តដែរ ។ គ្រាន់តែឮពាក្យថាម៉ែឪ ក៏ធ្វើកូនឱ្យក្សាន្តចិត្តបានដែរ នេះបានចំជា "*ព្រះរបស់កូន*" ។

## បទទីពីរ

## កូនជាទ្រព្យនៃមនុស្ស

ពុទ្ធភាសិត

ម៉ែ ពង្ផៃ

តាំងពីកាលដែលកូនចូលមកចាប់បដិសន្ធិនៅក្នុងឧទរម៉ែ យកឧទរម៉ែជាកន្លែងកខួន ម៉ែផ្លាស់ភាពពីស្ត្រីធម្មតាទៅជាស្ត្រីមានគភ៌ម៉ែគិតថា " *ម៉ែមានកូនហើយ* " ។ តពីកាលនោះមកម៉ែមានអាការៈប្លែកៗនៅក្នុងខ្លួនជាអាការៈដែលម៉ែមិនធ្លាប់បានដឹងដូច្នោះមកកាលមុនឡើយ (សម្រាប់ម៉ែមានបឋមគភ៌) គឺម៉ែមានអាការៈអស់កម្លាំងល្ហិតល្ហៃ វិលមុខចង្អោររឿយៗ មិនស្រឡះស្រឡុំក្នុងខ្លួនប្រាណដូចធម្មតាដើមទេ ឬម៉ែចង់បរិភោគអាហារនេះនោះជាដើមតែម៉ែមិនដឹងថាអាការៈប្លែកទាំងនេះជាអ្វីទេ ម៉ែដឹងថាម៉ែមានកូនប៉ុណ្ណោះ ។ អាការៈប្លែកទាំងនេះបុរាណចារ្យលោកហៅថា " *ការចាញ់ផ្ទៃ ឬចាញ់កូន* " ។

ចំណេរមក ម៉ែប្រុងប្រៀបរក្សាខ្លួន ប្រយ័ត្នប្រយ៉ែងគ្រប់ឥរិយាបថមិនហ៊ានរត់ឬដើរលឿនខ្លាំងពេកទេថ្នមខ្លួនមិនហ៊ានឱ្យរលកដង្គំដល់កូនសូម្បីតែចំណីអាហារណាដែលធ្លាប់ឆ្ងាញ់ពិសាមិនហ៊ានបរិភោគតាមចិត្តចង់ទេ ដូចជាអាហារមានរសជាតិជូរពេក ប្រៃពេក ហឹរពេកជាដើម ម៉ែ

ព្យាយាមវៀរបង់ឬព្យាយាមអត់ដើម្បីជាសុខដល់កូនដែលនៅក្នុងផ្ទៃ មិនតែប៉ុណ្ណោះម៉ែខំស្វះស្វែងរកថ្នាំមករក្សាគភ៌ទៀតថ្នាំណាដែលគេអួតថារក្សាគភ៌បានសុខ ម៉ែខំដើរទៅរកយកមកប្រើ ថ្នាំខ្លះដែលម៉ែមិនដែលដឹងមិនដែលឮ ឬមិនដែលចូលចិត្តប្រើដូចជាថ្នាំមានជាតិស្រាជាដើមម៉ែខំត្រដររផឹកដើម្បីឱ្យកូនដែលនៅក្នុងផ្ទៃមានសុខភាពបរិបូរណ៍ គ្រូពេទ្យពូកែ មាននៅទីណាទោះឆ្ងាយប៉ុន្មានម៉ែមិនរុញរាទេ ម៉ែស៊ូដើរទៅទីនោះទៅសូមជួយព្យាបាលដើម្បីឱ្យកូនម៉ែដែលនៅក្នុងផ្ទៃមានជីវិតបានឃើញពន្លឺព្រះអាទិត្យនឹងគេ។ សេចក្ដីរីករាយសប្បាយណាដែលនាំឱ្យមានភ័យដល់កូនម៉ែព្យាយាមវៀរបង់ វាព្រោះតែជីវិតកូន ។ សេចក្ដីគួរយល់ថាកូនមកដេកក្នុងផ្ទៃម៉ែប្រាកដជានាំយកទុក្ខមកឱ្យម៉ែ ឱ្យម៉ែលំបាកគ្រប់យ៉ាងឱ្យម៉ែទៅជាមានគ្រោះអន្តរាយព្រោះម៉ែត្រូវរវាំងប្រយ័ត្នគ្រប់ឥរិយាបថម៉ែមិនព្រមឱ្យសប្បាយតាមចិត្តម៉ែចង់ទេ គិតឱ្យតែកូនបានសុខស្រួល ម៉ែខំរក្សាគភ៌ដូចជាវត្ថុមានតម្លៃកាត់ថ្លៃមិនបាន ។

ពេលម៉ែកំពុងពផ្ទៃម៉ែចំបែងចិត្ត ម៉ែចង់ដឹងថាកូនម៉ែដូចម្ដេចប្រុស ឬស្រី ល្អ ឬអាក្រក់ ស ឬខ្មៅ ខ្លៅល្ងង់ ឬឆ្លៀវឆ្លាត មានបុណ្យ ឬឥតបុណ្យ ម៉ែចេះតែគិតមមៃថា កូនម៉ែដូចម្ដេចទៅអេះ! ហើយម៉ែបែបន់ព្រះសំពះទេវតាសូមឱ្យកូនម៉ែបានជាកូនប្រសើរ ។ ម៉ែនឹកស្មានថាកូនម៉ែជាប្រុសព្រោះម៉ែយល់សប្ដិឃើញអ្វីមួយដែលមានទំនងជាភេទប្រុស



បើឲ្យពេទ្យពិនិត្យជួយថែទាំជីវិតកូនក្នុង
ពោះឲ្យបានល្អស្រួលឲ្យបានចម្រើនពេញ
ព្រះរាជមិត្តនឹងគេ.

ម៉ែនឹកថាកូនជាស្រីព្រោះម៉ែយល់សប្តិឃើញអ្វីមួយមានសភាពជាស្រី ពុំនោះទេម៉ែនឹកថាកូនម៉ែជាប្រុសស្រីទៅតាមពាក្យលោកតាលោកយាយ ឬញាតិមិត្តនិយាយប្រាប់។ ជួនកាលដោយគិតខ្លាំងពេកម៉ែដើរទៅរកហោរ ឱ្យគន់គូរមើល.ឱ្យទាយមើលថ្ងៃខែឆ្នាំឱ្យដឹងថា តើកូនម៉ែដូចម្តេច? បើហោរទាយថាកូនម៉ែល្អ មានបុណ្យវាសនាប្រសើរណាស់ នុ៎ះម៉ែរីករាយសប្បាយចិត្តក្រៃលែង។ម៉ែព្យាយាមរក្សាគភ៌បែបនេះអស់ដប់ខែបរិបូរណ៍ ដោយទឹកចិត្តតែមួយថា " *ចង់ឱ្យកូនរស់* " ។

សេចក្តីរៀបរាប់មកនេះមិនបានល្អិតល្អន់ទេ ព្រោះភាសាសរសេរ មិនដូចភាសាចេញពីទឹកចិត្តម៉ែ.តែមើលទៅឃើញថាភារៈនេះពិតជាធ្ងន់ មែនមិនមែនធូរស្រាល ធ្ងន់គណនាត្រារាប់ពុំបាន។ យើងជាកូនគ្រប់គ្នា គន់គិតមើលចុះ!ម៉ែរក្សាគភ៌អស់វេលាដប់ខែ មិនមែនលំបាកតិចទេ បានជាលោកពោលទុកថាភារៈម៉ែធ្ងន់ក្រៃលែងធ្ងន់ លំបាកសែនលំបាកជាងភារៈដទៃៗទាំងអស់ជាភារៈដែលនរណាៗមិនអាចជួយសំរាលបាន កូនដែលរស់នៅបានក៏រស់នៅបានដោយអាស្រ័យទឹកចិត្តនិងកម្លាំងចិត្តម៉ែ កម្លាំងនេះជ្រាលជ្រៅណាស់មិនមានអ្វីអាចនឹងយកទៅវាយតម្លៃឱ្យត្រឹមស្មើបានឡើយ បើទុកជាកូនតាំងចិត្តថានឹងសងវិញ ក៏មិនដឹងជានឹងបានអ្វីយកមកធ្វើជាថ្នូរសងកម្លាំងចិត្តកម្លាំងកាយម៉ែដូចម្តេចបានដែរ សូម្បីតែមួយចម្រៀកសក់ក៏ពុំត្រឹមស្មើបានឡើយ។ ទោះបីភារៈពផ្ទៃ

របស់ម៉ែមានទម្ងន់ធ្ងន់បដិសេធមិនបានម្ល៉ឹងៗហើយក៏នៅមានកូនអកត្តញ្ញូ រមិលគុណម៉ែ កូននេះចំជាកូនចិត្តខ្មៅដូចកូនសត្វតិរិច្ឆានមែន។ ឱ! មុខ គួរឱ្យអាណិតចិត្តម៉ែនេះដែរ ព្រោះមានគ្រោះកាចទៅពផ្ទៃកូនចង្រៃ ព កូនភ្លើង ពឥតប្រយោជន៍ដូចពផែនដីធ្ងន់ឥតអំពើ ពិតណាស់ទៅហើយ ពផ្ទៃកូនអកត្តញ្ញូដូចពដុំដែកក្រហម ពដោយភ្លើង ពឆេះខ្លួន។ កូនម៉ែ គ្រប់រូបគួរគិត បើគិតទៅមិនឃើញទម្ងន់ម៉ែពផ្ទៃអស់ងប់ខែទេ គិតទៅ ទៀតជញ្ជឹងគិតកុំឈប់ មើលក្នុងខ្លួនឱ្យឃើញថាខ្លួនអាត្មានេះជាសាច់ ជាឈាមម៉ែនៅស្រស់ៗហើយត្រូវគោរពប្រណិប័តន៍ម៉ែឪ ជា "ព្រះ" ពផ្ទៃ ខ្លួនទៅតាមធម៌កុំបីខាន ។

# បទទីបី

## មាតាធ្វើការកម្រ

### មង្គលត្ថទីបនី

## ម៉ែ ឆ្លងទន្លេ

ម៉ែពពោះផ្ទៃគ្រប់ដប់ខែហើយដល់ពេលម៉ែឆ្លងទន្លេ ។ យើងដឹងថា ការឆ្លងទន្លេដោយទូកតែងមានភ័យមានគ្រោះអន្តរាយដល់ជីវិតព្រោះក្នុង រដូវខ្លះមានទឹកជំនន់ឡើងលិចវាលល្ហល្ហេវល្ហាចល្ហឹម មានខ្សែទឹកហូរ ខ្លាញ់ មានខ្យល់ព្យុះបោកបក់ខ្លាំង រលកបោកផ្កាត្រែងមើលទៅមុខគួរ សម្បើមណាស់។គេឆ្លងទន្លេរួចម្តងៗឈ្មោះថាមានភ័ព្វសំណាង។បុរាណ លោកយកពាក្យឆ្លងទន្លេនេះមកប្រដូចនឹងការប្រសូតិកូនរបស់ម៉ែ ដែលគ្រប់រូបតែងតែឆ្លងហើយប្រទះប៉ះទង្គិចគ្រោះអន្តរាយដល់ជីវិតម៉ែ រឿយៗដូចអ្នកឆ្លងទន្លេដែរ ម៉ែឆ្លងរួចម្តងៗ ឈ្មោះថាមានភ័ព្វវាសនាធំ ណាស់។

ពេលជិតឆ្លងទន្លេ ម៉ែរៀបចំខ្លួនទុកមុន អ្វីៗនៅក្នុងផ្ទះម៉ែរៀបចំ ដាក់ស្រេច ម៉ែសួររកឆ្មបឬគ្រូពេទ្យថា : នៅប៉ុន្មានថ្ងៃទៀតនឹងដល់ពេល ប្រសូតិហើយម៉ែដុតធូបបន់ព្រះសំពះទេវតាសុំឱ្យម៉ែឆ្លងទន្លេដោយសុវត្ថិ ភាពម៉ែប្រាប់ដំណឹងនេះដល់មាតាបិតា ជីដូនជីតានិងអ្នកស្និទ្ធិស្នាលនៅ



ជិតខាងសុំឱ្យមកជួយជីវិតម៉ែនិងកូនម៉ែ ម៉ែភ័យអរៗជានិច្ចម៉ែភ័យមុខក្រៀមក្រំព្រោះធ្លាប់ឃើញអ្នកជិតខាងខ្លះមានគ្រោះថ្នាក់ដល់បាត់បង់ជីវិតព្រោះតែឆ្លងទន្លេនេះ ម៉ែអរមុខមាត់រីករាយព្រោះជិតបានឃើញមុខកូនម៉ែហើយ ។ ការប្រុងប្រយ័ត្នប្រសូតិនេះដូចជាការប្រុងប្រយ័ត្នឆ្លងទន្លេដែរ។ ហេតុដូច្នេះហើយបានជាពេលឆ្លងទន្លេម្តងៗឃើញមានមាតាបិតា ឱដូនជីតាញាតិមិត្រមកជួបជុំគ្នារហង់ក្រៀមខ្លួនប្រុងជួយ មុខក្រៀមក្រំមិនស្រស់គ្រប់គ្នាទេ ចេះតែខ្សិបខ្សៀវពិគ្រោះគ្នាជានិច្ច។ ម៉ែឆ្លងទន្លេរួចហើយដោយសុវត្ថិភាពអ្នកទាំងអស់គ្នាមុខរីកដូចផ្កាឈូកសួរគ្នីគ្នាអ៊ូរអរថា ម៉េចទៅអ៊ីយ! ស្រីឬប្រុស? បានស្រីឬប្រុសក្តីណា ឮសួរតែមាត់ឱ្យពរជ័យដោយរីករាយសប្បាយចិត្ត ហើយលាន់មាត់គ្រប់គ្នាថា "រួចគ្រោះហើយ" ។

ចំណែកម៉ែលុះឆ្លងទន្លេហើយឮសួរកូនម៉ែយំ ម៉ែភ្លេចឈឺចាប់ក្នុងសព៌ាង្គកាយ ម៉ែទារសុំយកកូនមកមើលព្រោះម៉ែពុំទាន់បានឃើញមុខឃើញមុខកូនហើយ ម៉ែក្សាន្តចិត្តស្ទើរតែបាត់ឈឺចាប់ ។ តទៅម៉ែរងទុក្ខវេទនា ម៉ែអាំងភ្លើងក្តៅដូចគេដុតទាំងរស់ ម៉ែផឹកទឹកអំបិលប្រៃនេះហៅប្រៃ ម៉ែអត់ទ្រាំក្តៅ អត់ទ្រាំប្រៃព្រោះតែជីវិតកូន ។

ដោយមានភ័យអាសន្នដូចពោលមកនេះហើយ បានជាព្រះសម្មាស ម្ពុទ្ធទ្រង់អនុញ្ញាតឱ្យទាយកទាយិកាប្រគេនអច្ចេកចីវរចំពោះព្រះសង្ឃ

ក្នុងកាលពិសេស ។ រឿងអច្ចេកចីវរនេះបើយើងកុំគិតពីរូបពាក្យខ្លាំង ពេក គិតយកតែសេចក្ដីឱ្យស្ដាប់បានងាយ គួរតែប្រែថា "ចីវរអាសន្ន" ព្រោះចីវរនេះត្រូវប្រគេនព្រះសង្ឃដោយប្រញាប់ប្រញាល់ឱ្យទាន់ខ្លួន មានជីវិតរស់នៅគឺត្រូវប្រគេនចីវរនេះបានមុនកាល១០ថ្ងៃអំពីថ្ងៃបវារ-ណាគឺបានដល់ថ្ងៃ៦កើតរហូតដល់ថ្ងៃ១៥កើតខែអស្សុជដែលជាថ្ងៃបវារ-ណា បើមានទាយកទាយិកាមានសទ្ធាប្រាថ្នាប្រគេនព្រះសង្ឃ ព្រះសម្មា-សម្ពុទ្ធទ្រង់អនុញ្ញាតឱ្យភិក្ខុទទួលចីវរនេះបាន មិនចាំបាច់រង់ចាំដល់ចីវរកាល គឺវេលាដែលភិក្ខុមានអំណាចស្វែងរកសំពត់ចីវរដែលលោកកំណត់ទុកតាំងពីថ្ងៃបវារណាចេញវស្សាទៅដល់ថ្ងៃ១៥កើតខែកត្តិកនោះទេ ។

មូលហេតុដែលនាំឱ្យកើតអច្ចេកចីវរនេះឡើង មកពីអ្នកមានសទ្ធាពីរពួក ពួកទីមួយជាទាយកអ្នកមានសទ្ធាតែជាប់ដោយរាជការសង្គ្រាម ឬឈឺចាប់ធ្ងន់ពេកមានបារម្ភដល់ជីវិតនឹកក្រែងមិនអាចនឹងត្រឡប់មកទាន់ចីវរកាលវិញហើយសូមឱកាសប្រគេនចីវរមុន ពួកទីពីរជាទាយិកាមានសទ្ធាដែលមានគភ៌ចាស់ ហើយជិតដល់ពេលឆ្លងទន្លេក្នុងវេលាមិនទាន់ចេញវស្សាគិតថាចាំឆ្លងទន្លេហើយសឹមធ្វើខ្លាចក្រែងមានគ្រោះអន្តរាយដល់ជីវិតស្លាប់ចោលទៅមុនខានបានបំពេញកុសលព្រោះឆ្លងទន្លេមានភ័យដូចជាសង្គ្រាមដែរច្រើនតែមានអន្តរាយដល់ជីវិត កម្រនឹងរស់រានមានជីវិតណាស់ហើយមិនបានប្រគេនចីវរតាមកាលវេលាដែលកំណត់ទុក

បានក៏ប្រញាប់ប្រញាល់យកឱកាសនេះប្រគេនអច្ចេកចីវរឱ្យទាន់ខ្លួនបាន រស់ភ្នែកមើលឃើញ ហេតុនេះហើយបានជាចីវរនេះហៅថាអច្ចេកចីវរ ប្រែថា "ចីវរអាសន្ន" ។ លំដាប់តមក អ្នកមានសទ្ធានិយមធ្វើគ្រប់គ្នាទូទៅមិនប្រកាន់ថាជនពួកនេះឬជនពួកនោះទើបធ្វើបាននោះឡើយ ប្រកាន់ត្រឹមកាលវេលាប៉ុណ្ណោះ ។ ការដឹងមូលហេតុនៃអច្ចេកចីវរនេះ នាំឱ្យគិតដល់ជីវិតម៉ែគ្រប់រូបដែលធ្លាប់ឆ្លងទន្លេធ្លាប់ធ្វើសង្គ្រាមមកច្រើនដង ហើយគិតថាក្នុងវេលានេះម៉ែធ្លាប់ប្រយុទ្ធនិងទុក្ខធ្ងន់ៗមកច្រើនដងហើយ ម៉ែកូនណាក៏ដូចម៉ែកូនណាដែរ តែម៉ែខ្លះមានបុណ្យជួយ ជួយម៉ែឱ្យឆ្លងទន្លេដោយសួស្ដី ឱ្យម៉ែបានឃើញមុខកូនម៉ែ ។ ឯកូនម៉ែក៏មានបុណ្យដោយសារម៉ែដែរព្រោះកូនមិនកំព្រា កូនមិនអនាថាកើតមកមានម៉ែរក្សា ម៉ែត ម៉ែបីបមថ្នាក់ថ្នម ម៉ែគ្រង ម៉ែឱប ម៉ែបបោសអង្អែលល្ងងលោម ម៉ែបំពេចិញ្ចឹមឱ្យទាល់តែមានវ័យវឌ្ឍនការធំឡើង ។ កូនដែលមានម៉ែជាទេពតារក្សាគិតឱ្យសព្វគ្រប់ទៅឃើញថាម៉ែមិនមែនគ្រាន់តែជាម៉ែទេ គឺម៉ែជាបុណ្យរបស់កូនទៀតផង ព្រោះកូនមានបុណ្យដោយអាស្រ័យម៉ែជួយ បើមិនមានម៉ែសមកូននឹងរងទុក្ខវេទនាពិតឥតសង្ស័យឡើយ ព្រោះកូនកំព្រាមិនមានម៉ែជាទេពតាជួយដូចកូនដែលមានម៉ែ ។ តពីឆ្លងទន្លេមកម៉ែឪ មានធ្វើពិធីផ្សេងៗទៀតទៅតាមប្រពៃណីនិយមដើម្បីឱ្យកូនមានមង្គលសិរីសួស្ដីមានអាយុវែង មង្គលកោរសក់ព្រៃ មង្គលបំបើកភ្នែក



មង្គលឱ្យនាម ។ មង្គលទាំងនេះម៉ែឪ អញ្ជើញចាស់ទុំមកជួបជុំ ហើយប្រសិទ្ធិពរចងដៃឱ្យកូនម៉ែ ឱ្យកូនបានល្អប្រសើរតទៅអនាគត ។ អ្វីដែលនាំឱ្យសុខចំរើនម៉ែឪធ្វើតាមទាំងអស់ ការធ្វើនេះនឹងថាម៉ែឪឆោតល្ងង់ក៏បាន តែដោយពិតម៉ែឪធ្វើ ទៅតាមប្រពៃណីនិយមដែលគេធ្លាប់ធ្វើត១គ្នាមកដោយជឿជាក់ថាបានគាប់ប្រសើរដោយពិសេសម៉ែយល់ថាឱ្យកូនបានសុខចំរើនបាន មានអាយុរស់នៅវែងឆ្ងាយបើមានផ្កាំផ្តងក៏គួរឱ្យអភ័យដល់ម៉ែដែរ បើម៉ែមានការសិក្សាបរិបូណ៌យល់ការអស់នេះពិតប្រាកដមុខជាម៉ែគ្រប់រូបមិនព្រមធ្វើឱ្យខុសឃ្លាតពីតម្រាទេ និយាយខ្លីប៉ុណ្ណោះគង់យើងគ្រប់គ្នាឃើញចិត្តម៉ែហើយ ប្រាកដជាម៉ែមានចិត្តតែមួយគឺចង់ចិញ្ចឹមឱ្យកូនរស់ បានជាយើងគ្រប់គ្នារស់នៅរហូតមកដល់សព្វថ្ងៃនេះ ដូច្នេះហើយបានជាលោកពោលទុកមកថា បណ្តាម៉ែឪទាំងពីរនាក់នេះ " ម៉ែធ្វើការកម្រគឺឆ្លងទន្លេតែម្នាក់ឯង " ។

*******************************************************

"- ដង្កូវឡើងទំលើក្បាលសាធារណជនទាំងឡាយបាន ព្រោះនៅលាយឡំជាមួយកំរងផ្កា ដុំថ្មដែលអ្នកធំលើកដំកើងហើយក៏ក្លាយទៅជាភាពទេវតាពូកែសក្តិសិទ្ធិ " ។

"- របស់ទ្រព្យដែលនៅលើកំពូលភ្នំខាងឧទយាទិត្យតែងបានទទួលពន្លឺស្វាងរុងរឿងព្រោះនៅជិតព្រះអាទិត្យយ៉ាងណា ជនហីនជាតិ វណ្ណៈថោក តែងបានទទួលការចេះដឹងជាពន្លឺ ព្រោះនៅជិតលោកអ្នកសប្បុរសយ៉ាងនោះដែរ" ។

"- អ្នកមានគុណគាប់តែងដឹងល្អនិងអាក្រក់ អ្នកមានគុណគាប់នោះបើទៅសេពគប់មនុស្សអាក្រក់វិញ ដូចស្ទឹងមានទឹកដ៏ថ្លាហើយដោយរសជាតិល្អ លុះហូរចូលសមុទ្រហើយក៏ក្លាយទៅជាមានរសប្រៃផឹកមិនបាន " ។

ដកស្រង់ពី ហិតោបទេស - ទំព័រ ២១ ភាគ១

*******************************************************

## បទទីបួន

### សេពគប់អ្នកណា ទៅជាអ្នកនោះ

#### មង្គលត្ថទីបនី

#### ម៉ែចិញ្ចឹមកូន

LIBRARY BUDDHIST INSTITUTE

ម៉ែឪបង្កើតកូនមកហើយមានភារៈចិញ្ចឹមកូនឱ្យរស់នៅតទៅទៀត។ ការចិញ្ចឹមកូនឱ្យរស់មិនមែនជាភារៈងាយទេ ជាភារៈធ្ងន់កម្រក្រៃណាស់។ ក្នុងការចិញ្ចឹមនេះ ម៉ែឪត្រូវប្រើការព្យាយាមបំផុត ត្រូវប្រើកម្លាំងកាយ កម្លាំងចិត្ត កម្លាំងទ្រព្យ ទើបសំរេចបាន ។ ស្ត្រីដែលមិនមែនជាមាតា ចិញ្ចឹមកូនឱ្យរស់បានដែរ តែបើមិនរស់ក៏មិនរំពល់ចិត្តព្រោះខ្វះខាតទឹកចិត្តប្រកបដោយព្រហ្មវិហារធម៌ ។ ចំណែកម៉ែវិញ ប្រាកដជាចិញ្ចឹមកូនដោយព្រហ្មវិហារធម៌ ចង់ឱ្យកូនរស់ពិត១ បើបែរជាមិនរស់វិញ ម៉ែមិនអស់ចិត្តទេ ដូច្នេះខ្ញុំស្ទើរតែចង់តែនិយាយថា "ក្រៅពីម៉ែឪ មិនមាននរណាចិញ្ចឹមកូនឱ្យរស់បានទេ" ។

រឿងម៉ែឪ ចិញ្ចឹមកូនមានច្រើនប្រការណាស់ ប៉ាកាខ្ញុំសរសេរមិនចេញឱ្យគ្រប់គ្រាន់សោះ ខ្ញុំសរសេរបណ្តើរនឹកបណ្តើរថា បើប្រសិនជាម៉ែគ្រប់រូបមិនព្រមអួតសរសើរចិត្តម៉ែទេ ទុកឱ្យកូនម៉ែពិចារណាមើលយកដោយខ្លួនឯងចុះ ។ ទឹកប៉ាកាខ្ញុំនេះ បើមានការថ្កាំថ្កងដោយហេតុ

កូនបៅកកោរយចំណីស្មើដាក់អាហារ ដល់ខ្នាក់កោយចំណី រកស់ពីព្រង
ពោយចំណីគ្នាយកទៅដាក់ទឹកដោះដ៏ល្អបរិសុទ្ធ សម្រាប់ចិញ្ចឹម
ជីវិតកូន, កូនបរកត្រូវតែមើលបរកថែរក្សាដោយដុះដោយចាក់
ធ្វើការកាត់ឆាប់ដោយកូនដោយទឹកដោះ
ម្ដាយចិញ្ចឹម.



ណាមួយ ឬមិនដិតដល់ទឹកចិត្តម៉ែឪដោយប្រការទាំងពួង ខ្ញុំសង្ឃឹមថា ម៉ែឪគ្រប់រូបគង់អភ័យទោសឱ្យរូបខ្ញុំដោយពិត ព្រោះខ្ញុំមិនដឹងកិច្ចការម៉ែឪនេះសព្វគ្រប់ទេ ។

ធម៌ម៉ែឪចិញ្ចឹមកូន យើងតែងបានឃើញនឹងភ្នែកយើងគ្រប់គ្នា ហើយយើងឃើញថា តពីពេលឆ្លងទន្លេមក ម៉ែចិញ្ចឹមកូនដោយទឹកដោះម៉ែ, ម៉ែបំបៅយប់ថ្ងៃ, ម៉ែបីបមថ្នាក់ថ្នមមិនឱ្យរលកដង្គំ, កូនយំម៉ែលួងលោម, ម៉ែផ្ងូតទឹក, ម៉ែផ្តេកម៉ែយោល, ម៉ែបំពេ, ម៉ែរវាំងប្រយ័ត្នគ្រប់ពេលវេលា ។ ម៉ែធ្វើយ៉ាងនេះរហូតដល់កូនបានធំចេះក្រឡាប់ ចេះញញឹម ចេះអង្គុយ ចេះក្រោក ចេះឈរ ចេះដើរដួល ចេះនិយាយ ចេះដើរ ចេះរត់ ។ ម៉ែអត់ទ្រាំរងទុក្ខវេទនានេះ អស់វេលាច្រើនឆ្នាំ មិនមែនអស់វេលាតិចទេ ។ បើម៉ែឪ បង្កើតកូនមកហើយមិនមានមេត្តា គ្រាន់តែទុកកូនចោលនៅកៀនជញ្ជាំង កូនបាត់បង់ជីវិតលែងឃើញពន្លឺព្រះអាទិត្យទៅហើយមែនទេ ? ការទាំងនេះកម្រក្រៃក្រៃមែន។ ចូរមើល ! កាលមុនពីកាលដែលម៉ែមិនមានកូន ម៉ែមិនដែលដេកភ័យ, ដេកស្ដុតស្មារតីទេ, ម៉ែដេកសប្បាយ, ដេកស្រួលពេញភ្នែក, កាលម៉ែមានកូនមកដេកនៅក្បែរម៉ែហើយ ម៉ែលែងបានដេកសុខស្រួលទៀតហើយ ព្រោះម៉ែត្រូវប្រយ័ត្នរវាំងមើលកូនគ្រប់ពេលវេលា ដូចជាពេលដេកម៉ែត្រូវលួងលោមឱ្យកូនដេកមុនសិន កូនដេកមិនទាន់លក់ដរាបណាម៉ែធ្មេចភ្នែកដេកមិនលក់ ដរាប

នោះ ម៉ែមើលទៅឃើញកូនដេកលក់ហើយទើបម៉ែដេកជាក្រោយ ជួន កាលម៉ែមិនទាន់ទាំងបានប្រាសខ្នងដល់កន្ទេលផងកូនម៉ែភ្ញាក់ឡើងយំ ម៉ែស្ទុះទៅមើល ស្ទុះទាំងទទឹងខ្លួនហាក់ដូចជាម៉ែភ័យនឹងកូនណាស់ ទៅ ប្រវេប្រវាបីពថ្នាក់ថ្នមហើយមើលខ្លាចមានសត្វចង្រៃវាទិច វាខាំ កូនម៉ែ ហើយបបោសអង្អែល លួងលោមឱ្យកូនដេកទៅវិញ ទើបម៉ែធ្មេចភ្នែក លក់បាន បើម្ទឹង១តើកូនគ្រប់គ្នាថាយ៉ាងម៉េច?

កាលមិនទាន់បានជាម៉ែ ម៉ែទាំងឡាយតែងស្រឡាញ់ខ្លួន សំអាត ខ្លួន ការពារមិនហ៊ានឱ្យសៅហ្មងទេ កាលម៉ែមានកូន ម៉ែយកកាយស្អាត របស់ម៉ែជាកន្ទោរ ជាបង្គន់ ជាភាជន៍រងចាប់គ្រឿងស្មោកគ្រោកកូន កូន បន្ទោរបង់មូត្រលាមក កំអួត សំបោរដាក់លើម៉ែបានតាមចិត្ត ម៉ែមិនធ្វើ មុខជូរទេ ពីកាលមុនដែលមិនមានកូន ម៉ែខ្ពើមរអើមគ្រឿងស្មោកគ្រោក ទាំងនេះណាស់ បើឃើញមាននៅទីណាហើយ ម៉ែគេចចៀសវាងចេញ ពីទីនោះទៅឆ្ងាយភ្លាម តែវេលាដែលម៉ែមានកូនហើយ ម៉ែផ្លាស់ចិត្តនេះ ចេញចោលស្រឡះ ទាំងនេះមិនមែនម៉ែស្មោកគ្រោកទេ តែព្រោះម៉ែស្រ ឡាញ់កូន, អាណិតកូន, មេត្តាកូន, ចង់ឱ្យកូនស្អាត កាលឃើញកូនមាន មន្ទិលសៅហ្មងទាំងនេះហើយ ម៉ែមិនគេចចេញដូចកាលមុនទេ ម៉ែបែរ ជាចូលទៅរកដោយទឹកមុខញញឹមដដែល ទៅប្រវេ ប្រវាបីបមថ្នាក់ថ្នម លាងជូតសំអាតកូនដោយដៃស្អាត ម៉ែយកដៃស្អាតទៅចាប់ ទៅពាល់

ទៅកាន់គ្រឿងស្មោកគ្រោកអស់ទាំងនេះយ៉ាងស្និទ្ធ ហាក់ដូចជារបស់អស់នេះជារបស់ក្រអូបប្រសើរទៅវិញ មុខគួរឱ្យស្ញើចចិត្តម៉ែមែន ។ នេះហើយហៅថាម៉ែ. មិនមែនម៉ែគេដូចម៉ែខ្លួនទេ ។ ស្ត្រីមិនមែនជាម៉ែហើយធ្វើនាទីជាម៉ែប្រាកដយ៉ាងម៉ែ. ចិត្តដូចម៉ែ មានឬទេ? មើលទៅមិនសូវមានទេក្នុងលោកយើងនេះ ។

សេចក្ដីពិត. មនុស្សតែងតែមានការប្រកាន់ខ្លួន មានការអៀនខ្មាសច្រើនជាធម្មតា ស្ត្រីភាពមិនដែលឱ្យអ្នកណាចាប់ប៉ះពាល់កាយទេ នេះជាគុណសម្បត្តិជាកិត្តិយស ដែលស្ត្រីគ្រប់រូបត្រូវតែស្ងួនគ្រងរក្សាដូចរក្សាជីវិត តែចំពោះកូន ម៉ែអនុញ្ញាតឱ្យចាប់ប៉ះពាល់បាន ដើរជាន់បាន ម៉ែមិនប្រកាន់ទោសពៃរ៍ទេ ។ បើកូនទារបោក្នុងទីកណ្ដាលមុខទីជនានុជនដោយអាណិតកូន ម៉ែភ្លេចអៀនខ្មាស ភ្លេចប្រកាន់អស់ ឈាមក្នុងទ្រូងម៉ែពិតៗក្លាយទៅជាទឹកក្សីរដោយព្រហ្មវិហារធម៌ ម៉ែត្រេកអរឱ្យកូនបៅៗទាល់តែទ្រូងរីងស្គាំងស្គម បើទុកជាម៉ែរ៉ូយស្រពន់ ក៏ម៉ែនៅតែករុណាកូនដរាប ។ ឱ! ចិត្តម៉ែប្រសើរអ្វីម្ល៉េះទេ !

មួយទៀតសត្វតូចតាចដូចជាស្រមោច, ស្រមើល, រុយ, មូស ជាដើម កាលពីដើមម៉ែហាក់ដូចជាមិនសូវស្អប់ឬមិនយកជាសត្រូវអ្វីទេ លុះម៉ែមានកូនហើយ ម៉ែយកវាជាសត្រូវ ម៉ែស្អប់វាណាស់ គ្រាន់តែឃើញសត្វទាំងនេះហើរមកជិតកូន ម៉ែក្នាញ់ជាទីបំផុត ភ័យខ្លាចក្រែងសត្វអស់

នេះវាទៅទិចទៅខាំកូន. មានជួនកាលម៉ែទប់ចិត្តមិនបានភ្ញាក់ធ្វើបាណាតិបាតមួយដងមួយកាលទៅ សូម្បីកូននៅក្នុងមុងហើយម៉ែនៅតែមិនទាន់ទុកចិត្ត ម៉ែរកសៃរកអ្វីមកបក់បោកដេញទៀត បើមានសត្វអ្វីមួយខាំកូនម៉ែយំ ម៉ែភ័យណាស់ហើយក្រេវក្រោធជេរស្តីប្រទេចសត្វនោះ ហើយរកប្រេងម្សៅទៅលាបស្រឡាបឱ្យកូនម៉ែ តទៅម៉ែរវាំងប្រយ័ត្នគយគន់រំពៃមើលមិនឱ្យសត្វចង្រៃទាំងនោះមកខាំកូនម៉ែទៀតបានឡើយ ។

កូនយំដោយភ័យខ្លាចអ្វីមួយ សម្លេងកូនយំនេះទៅចាក់ចុចចិត្តម៉ែឱ្យឈឺខ្លោចផ្សាហាក់ដូចជាសូវរំពាត់ដែលធ្លាក់ទៅលើខ្នងម៉ែ ម៉ែធ្វើព្រងើយពុំបានទេ ម៉ែក្រោកតឹងស្ទុះទៅរកកូនភ្លាម ទៅបីបមថ្នាក់ថ្នមកូនមកឱបនៅព្ទដើមទ្រូងដៃម៉ែបបោសអង្អែល មាត់ម៉ែលួងលោមដោយសំដីទន់ផ្អែម ម៉ែមិនខុសសោះ ម៉ែធ្វើជាម៉ែខុស ម៉ែជេរស្តីថ្កៃថ្នាតែផ្តាសទៅវិញ ឱ្យតែកូនម៉ែចាត់មាត់លែងយំ ទើបម៉ែនៅជាប្រក្រតីបាន ។

ពេលកូនឈឺ ម៉ែឈឺជាមួយផង ម៉ែមើលមុខកូនឈឺដោយភ្នែកទទឹកជោកដោយទឹកភ្នែក ជួនកាលម៉ែអត់ទ្រាំពុំបាន យំខ្សឹកខ្សួល រអាក់រអួលឥតក្សាន្តឡើយ ។ ហើយម៉ែទៅបែបន់ព្រះសំពះទេវតា សូមឱ្យកូនម៉ែជាសះស្បើយទៅ កូនម៉ែមិនជាសះស្បើយដរាបណាម៉ែហាក់ដូចនៅឈឺដរាបនោះ មានកាលកូនស៊ីមិនបាន ម៉ែក៏មិនស៊ីបានដែរ កូនដេកមិនលក់ ម៉ែដេកមិនលក់ដែរ កូនស្គាំងស្គមចិត្តម៉ែចង់ស្គាំងស្គមដូចកូនដែរ



ចិត្តម៉ែសង្រែងដូចមេអក ថាបើម៉ែអាចទទួលយកជម្ងឺកូនបាន ម៉ែសុខចិត្តទទួលយកមកឈឺជំនួសកូនម៉ែមិនចង់ឱ្យកូនឈឺសោះ. ឈឺម្ដងៗម៉ែកើតទុក្ខធំដេកមិនលក់បក់មិនរហើយ ចិត្តម៉ែក្រៀមក្រំទំទុក្ខជានិច្ចព្រោះតែជីវិតកូនសំឡាញ់ ។ ម៉ែមានព្រហ្មវិហារធម៌ជានិច្ច ថ្ងៃយប់ពេលដេកពេលដើរ ពេលស៊ី ម៉ែនឹកថា "កូនៗ" ចិត្តម៉ែនៅជាប់តែនឹងកូន ជីវិតម៉ែគឺជីវិតកូន ពេលសុខៗជាមួយគ្នា ពេលទុក្ខៗជាមួយគ្នា ។ ម៉ែចិញ្ចឹមកូនព្យាបាលកូន បីបមថ្នាក់ថ្នម បបោសអង្អែល លួងលោមឱ្យកូននៅបានសុខស្រួល មិនឱ្យរលកជង្គំទេ ចិត្តម៉ែហ៊ានលះបង់ជីវិតដើម្បីកូនដូចព្រះអរហន្ត ហ៊ានលះបង់ជីវិតដើម្បីសត្វលោកបានជាលោកពោលថា "ម៉ែឪជាព្រះអរហន្តរបស់កូន"។

រឿងម៉ែកូននេះមានសេចក្ដីប្លែកៗណាស់ ។ ជីវិតម៉ែមានទ្រព្យនិងម៉ែក្រីក្រចិញ្ចឹមកូនដោយទឹកចិត្តដូចគ្នា តែដោយទ្រព្យខុសគ្នាស្រឡះម៉ែមានទ្រព្យអាចផ្គាប់កូនបានគ្រប់យ៉ាងតាមចិត្តចង់ ឯម៉ែក្រីក្រធ្វើមិនបានតាមចិត្តចង់ទេ ។ ម៉ែក្រីក្រមិនមានគ្រឿងស្លៀកពាក់ល្អ មិនមានអាហារអនាម័យ សេនាសនអនាម័យថ្នាំឱសថវិសេសទេ ម៉ែក្រីក្រចិញ្ចឹមកូនតាមមានតាមបាន តែអស់ពីពោះពីពុងមិនមានលាក់លៀមទេ ហើយម៉ែរងទុក្ខវេទនាខ្លាំងណាស់ដូចជាពកូនដើររកស៊ីហាលភ្លៀងហាលខ្យល់ក្ដៅរងាមិនថាយប់ថ្ងៃទេ ពេលក្ដៅមិនមានឆ័ត្របាំងយកដៃបាំងកូន

ពេលរងាមិនមានភួយដណ្តប់យកដៃឱបកូន ពេលដើររកស៊ីដៃម្ខាងពកូន ដៃម្ខាងទូលកញ្ជើរ មានកាលខ្លះទូលបណ្តើរបំបៅបណ្តើរមានអកុសលអ្វី ជាងនេះទៅទៀត! ពេលកូនឈឺមិនមានថ្នាំវិសេសព្យាបាលទេ ប្រើថ្នាំផ្តេសផ្តាសតាមតែមានបាន ហើយទាល់គំនិតដុតធូបបន់ព្រះសំពះទេវតាសុំឱ្យកូនម៉ែជា ហើយក្រុងកូនក្នុងវង្ង់ដៃដូចសត្វក្រុងកូនវា។ទិដ្ឋភាពបែបនេះមុខគួរឱ្យវេទនាណាស់ ហើយគេឃើញមាននៅញឹកញយ នៅតាមជីវិតអ្នកស្រែចំការដែលក្រីក្រ ។ ម៉ែទាំងនេះមិនមែនចិត្តអាក្រក់ចំពោះកូនទេ ម៉ែចង់បំពេញចិត្តកូនណាស់ តែម៉ែក្រីក្រ។ សេចក្តីក្រីក្រនេះជាមារវាំងចិត្តម៉ែក្រីក្របានធូរចិត្តសោះ ។ ឱ ! សេចក្តីក្រីក្រអើយ ! ម្តេចអ្នកក៏បៀតបៀនចិត្តម៉ែឱ្យចំបែងខ្លាំងម្ល៉េះ ? ខ្ញុំបានឃើញជីវិតម៉ែក្រីក្រនៅស្រុកស្រែរឿយៗ ។ ម៉ែអ្នកស្រែស្លៀកពាក់មិនល្អទេ ក្បាលទូលកញ្ជើរ ដៃម្ខាងពកូនខ្ចី ដៃម្ខាងទៀតកាន់ខ្សែគោពីរបីដើរទៅស្រែ ជូនកាលគោប្រទាញទៅមុខទៅក្រោយកណ្តាលភ្លៀងទទឹកជោកខ្លួនដល់ស្រែយកសំពត់ធ្វើជាអង្រឹងឱ្យកូនដេក យោលបណ្តើរធ្វើការបណ្តើរ ហើយមិនសូវបានមើលល្បែងច្រៀងរាំ គ្រាន់លំហែចិត្តនឹងគេទេ ម៉ែក្រីក្រទាំងនេះឃើញកូនគេមានជីវភាពខ្ពង់ខ្ពស់ គឺមានស្លៀកពាក់ល្អមានមាសមានពេជ្រស៊ីស្រួលដេកនៅស្រួល. នឹកតូចចិត្តនឹងភ័ព្វសំណាងខ្លួនឯងស្រឡេះកើតមកមិនច្រឡំនឹងគេ ព្រោះតែក្តីក្រីក្របៀតបៀនមិនមានអ្វី

ទំនុកបំរុងកូនឱ្យដូចម៉ែអ្នកមាន. ឱ ចិត្តម៉ែក្រីក្រ! ។ ថាដើម្បីកូនហើយម៉ែធ្វើអ្វីបានទាំងអស់លែងខ្មាសលែងអៀនដូចកាលដើមម៉ែមិនចេះបំពេទេ អ្នកជិតខាងមិនដែលឮសូរសំលេងម៉ែច្រៀងម្តងសោះ តែដល់កាលម៉ែមានកូនគេឯងឮសំលេងម៉ែច្រៀងបំពេ សព្វបើគ្រាន់តែឱ្យកូនក្សាន្តដេកលក់ប៉ុណ្ណឹងម៉ែហ៊ានច្រៀងៗដោយសំលេងពិរោះជាប់ដោយទឹកមេត្តា កូនខឹងសំបាម្តេចម្តាឮសំលេងម៉ែ ហើយសម្ងំដេកលក់ទៅ ហាក់ដូចជាសំលេងម៉ែមានមេត្តាសណ្តំកូន.ព្រោះព្រំឱ្យកូនដេក។ ខ្ញុំព្យាយាមខំរកបទបំពេដែលម៉ែគ្រប់ ម៉ែធ្លាប់បំពេកូនតៗមក ហើយធ្វើចិត្តកូនឱ្យរីករាយ.ឱ្យត្រជាក់ត្រជុំ.ឱ្យក្សេមក្សាន្ត. ឱ្យសម្ងំនៅស្ងៀមនេះអស់កាលយូរតែរកមិនបានសព្វគ្រប់ទេ។តាមដំណឹងថាបទបំពេច្រើនបែបណាស់ តាមបែបបទអ្នកស្រុកតែទោះម្តេចម្តាសេចក្តីតែមួយគឺបំពេកូន ឱ្យកូនរីករាយសប្បាយចិត្ត. ក្សេមក្សាន្តចិត្ត។ បទបំពេថ្មីៗមានច្រើនដែរ មានរសមួយបែប តែមិនមែនផងម៉ែគឺមិនសុទ្ធទៅតាមដើមដែលផុសចេញពីដួងចិត្តម៉ែ។ បទបំពេនេះតាមធ្លាប់ឮមក។

## បទម៉ែបំពេកូនមួយបែប

| | |
|---|---|
| កូនអើយដេកទៅ | ពៅអើយកុំយំ |
| ទំរាំបាយងំ | ដើបឡើងហូបបាយ ។ |
| នៅលេងជិតៗ | កុំទៅលេងឆ្ងាយ |



ចំប៉ី ច្រៀងបំពេរកូន តាមរបៀប ចិត្តសាស្ត្រ
ដើម្បីឲ្យកូនឆាប់ងងុយ ឆាប់បំពេញទៅជាការ.

នៅលេងរៀងអាយ    រក្សាម៉ែឪ។
កូនអើយដេកទៅ    ម្ដាយនៅនេះទេ
ម្ដាយចាំបំពេ    យេលយោលអ្នកដេក។

**បទជីដូនបំពេចៅមួយបែប**

ជីដូននិងចៅ    និតនៅតែផ្ទះ
ម្ដាយនាងនឿយណាស់    ដកផងស្ទូងផង។
ទាំងដៃទាំងជើង    ទាំងមាត់ស្រែកផង
ឮស័ព្ទរំពង    បង្អើលចាបពូក។

**សាស្ត្រាព្រះគុណម៉ែជាច្បាប់បុរាណមានសេចក្ដីថា:**

ព្រះគុណលោកម្ដាយ    អ្នកយោលពីធ្លាយ    ហើយអ្នកច្រៀងផង
ខំប្រឹងធ្វើការ    តិចៗទៅហោង    យាសយោលកូនផង
បំពេបណ្ដើរ ។

ហះហ៊ីហះអ៊ី    ពៅរើយពៅរី    មាសអើយកុំយំ
សូរស័ព្ទអង្រឹង    ទ្រហឹងបន្សំ    ទំហំបាយធំ
ភ្ញាក់ឡើងហូបបាយ ។

មាសអើយអ្នកដេក    ម្ដាយយោលល្ហពេក    រំហើយឥតល្ហែ
អ្នកមាសដេកទៅ    ម្ដាយនៅនេះដែរ    ម្ដាយចាំបំពេ
យាសយោលឱ្យអ្នក ។

អ្នកអើយអ្នកដេក អ្នកកុំយំពេក ម្ដាយយោលឥតអាក់
ខ្យល់បក់រំភើយ រហើយត្រជាក់ ត្រសៀកត្រសាក់
ត្រសាយត្រសុំ ។
កូនមាសម្ដាយអើយ ម្ដាយយោលឱ្យហើយ សម្ងំដេកទៅ
ម្ដាយច្រៀងឱ្យស្ដាប់ ។
ឱៈឱស្រណោះផ្កា ក្លិនចន្ទក្រស្នា ក្រអូបថ្មីៗ
ដូចក្លិនមាសស្ងួន នឹមនួនពិសី ក្លិនជាប់នៅដៃ
ដូចក្លិនកូនពៅ ។

លោកឧកញ៉ាសុតន្តប្រីជាឥន្ទ ជាកវីល្បីឈ្មោះក្នុងសតវត្សរ៍ទី២០ តែងបទបំពេមួយមានរសបែបថ្មី ពិរោះមួយបែប ដូច្នេះ :

ឱល្ហែឱល្ហាត់ (ស្ងួន) ភ្ញាក់ឡើងពីព្រឹក ដាំស្លទៅស្រែ
ខំដកខំស្ទូង ឱ្យទាន់ដើមខែ តែធ្វើក្រោយគេ
ដីត្រជាក់ស្រូវមិនល្អ ។
កូនអើយដេកទៅ ចូរចៀមកូនក្រ បើឯងយំឡ (ស្ងួន)
ម៉ែទៅស្ទូងឯណាបាន ។
ដេកទៅពៅម៉ែ កុំឱ្យម៉ែកើតរំខាន បើម៉ែធ្វើស្រូវបាន
លក់ទិញកងមាសឱ្យកូនពាក់ ។
ឱល្ហែឱល្ហាក់ (ស្ងួន) បែកញើសសស្រាក់ ព្រោះចង់មានដូចគេ។

សុរិយង្គសុរិយេ (ស្ងួន) ល្ងាចហើយមាសមេ ដេកទៅណាចា ។
ម្ដាយថ្នាក់ថ្នមអ្នក ទុកតាងនេត្រា បើកូនធំកាលណា
ម្ដាយឱ្យបាទៅវត្ត ។
រៀនពុទ្ធវចនៈ អក្ខរពុទ្ធរតន៍ យោងម្ដាយឱ្យផុត
វដ្ដសង្សារអើយ ! ។

រឿងម៉ែចិញ្ចឹមកូនជារឿងវិចិត្តពិស្ដារណាស់ និយាយមិនមានទីបំផុតទេនិយាយកាត់ខ្លីពេក ហាក់ដូចជាកាត់សារៈម៉ែ និយាយវែងហួសប្រមាណក្រែងអ្នកផងនិយាយថា អួតម៉ែហួសខ្នាតពេក ។

នៅប្រទេសយើងគេច្រើនតែបន្ទោសថា ម៉ែខ្វះខាតការសិក្សា មិនចេះអនាម័យ មិនទាន់សម័យនិងគេបានជាកូនស្លាប់ច្រើនជាងរស់នៅ ។ ពិតមែនណាស់ទៅហើយ. តែគួរយើងសរសើរចិត្តម៉ែឱ្យណាស់ ត្បិតកូនម៉ែដែលរស់នៅសព្វថ្ងៃដោយកម្លាំងកាយម៉ែ.កម្លាំងចិត្តម៉ែ.កម្លាំងទ្រព្យម៉ែ ដោយសារដៃម៉ែពិតៗតាមម៉ែខ្វះការសិក្សា តាមម៉ែមិនចេះអនាម័យ តាមម៉ែក្រីក្រថាបើម៉ែចេះ ម៉ែមានវិជ្ជាគ្រប់គ្រាន់ ម៉ែមិនព្រមចិញ្ចឹមកូនក្រៅតម្រាទេ ព្រោះម៉ែមានព្រហ្មវិហារធម៌តែងតែរិះរករិធីវិសេសគ្រប់បែបគ្រប់យ៉ាងដើម្បីចិញ្ចឹមកូនឱ្យរស់ហើយឱ្យបានល្អជានិច្ចទោះម្ដេចម្ដា. ម៉ែប្រើព្យាយាមធំបំផុតចិញ្ចឹមកូនចង់ឱ្យកូនរស់ឱ្យបានធាត់ធំទោះជាកូនកើតមកខ្វិនខ្វាក់គថ្លង់ក៏ដោយក៏នៅតែកូនម៉ែ ព្រោះគោល

បំណងម៉ែមានតែប៉ុណ្ណេះ ម៉ែមិនគិតខាតបង់ មិនគិតនឿយហត់ទេ។ ម៉ែចិញ្ចឹមកូន.ម៉ែពិនិត្យមើលរាល់ទិនទិវារាត្រីបើឃើញថាកូនបានធំសមតាមប្រាថ្នាគឺឃើញកូនចេះក្រឡាប់.ចេះលូន. ចេះវារ.ចេះអង្គុយ. ចេះក្រោកចេះដើរតេះតាស់.ចេះដើរដួល. ចេះដើរស្រួល. ចេះរត់. ចេះញញឹមដាក់មុខម៉ែ.ចេះនិយាយហៅ ម៉ៈ ម៉ៈ ប៉ៈ ប៉ៈ បានហើយ ម៉ែរីករាយសប្បាយចិត្តខ្លាំងណាស់សប្បាយហៅសែនសប្បាយមិនដឹងជាមានអ្វីមកនិយាយឱ្យចំចិត្តម៉ែសប្បាយបានទេ។ ម៉ែឮសំលេងកូនហៅម៉ែបានហៅឪ បានសំឡេងនេះសូម្បីមិនច្បាស់លាស់. តែជាសំឡេងពិរោះរកអ្វីមកប្រៀបពុំបានឡើយសឹងតែថាពិរោះជាងភ្លេងថានសួគ៌ទៅទៀត បើទុកជាសំឡេងកូនជេរម៉ែក៏ពិរោះដែរ វាអស់បើនឹងនិយាយថាម៉េចកើតហើយ ព្រោះចិត្តម៉ែជាចិត្តព្រះអរហន្តរបស់កូនពិតៗ ។ ដើម្បីនឹងបំពេញចិត្តម៉ែដែលសប្បាយម៉ែចាប់កូនបីជាប់នៅដើមទ្រូងជប់ថើបដោយសេចក្តីស្នេហាដ៏មោះមុត ធ្វើប៉ុណ្ណេះទើបអាចជួយសំរាលចិត្តម៉ែដែលស្រឡាញ់កូន ឱ្យធូរស្រាលក្សេមក្សាន្តបានខ្លះ ហើយម៉ែពកូនទៅនិយាយបង្អួតប្រាប់យាយប្រាប់តាប្រាប់បងប្អូនថាកូនម៉ែចេះនិយាយបានហើយឱ្យយាយតាបងប្អូនជួយអរម៉ែថែមទៀត ។ ម៉ែឪ យកកម្លាំងទាំងមូលទៅប្រើដើម្បីកូនទាំងនេះហើយបានជាព្រះសម្មាសម្ពុទ្ធសំដែងទុកថាម៉ែឪ ជា "*ព្រះព្រហ្ម*" ជា "*ទេវតាដើម*" ជា "អាចារ្យដើម" ជា "*អាហុនេយ្យបុគ្គល*" របស់កូន ព្រោះម៉ែឪមានឧបការច្រើនណាស់។

*******************************************************

"- មានប្រយោជន៍អ្វីចំពោះកូនដែលកើតហើយល្ងង់ផងមិនប្រកបដោយធម៌ផង? ដូចភ្នែកឈើមានប្រយោជន៍អ្វី? បានគ្រាន់ឈឺចាក់ដោតនាំឱ្យរំខានប៉ុណ្ណោះ"។

"- កូនមានគាប់គុណតែម្នាក់ជាកូនប្រសើរ កូនល្ងង់រាប់រយមិនប្រសើរទេ ដូចព្រះចន្ទតែមួយដួងអាចកំចាត់អន្ធការបានកងតារាទាំងឡាយកំចាត់បង់ងងឹតមិនបានឡើយ"។

"- គួរនឹងរាប់អ្នកមានកូនច្រើនថាគាប់ប្រសើរឬទេ? បើកូនទាំងឡាយនោះទុកដូចជានាឡិទទេក្នុងជង្រុក កូនតែម្នាក់ជាទីពឹងផ្អែកទំនុកបំរុងត្រកូលល្អជាជាងគេ្គ ឈ្មោះមាតាបិតាក៏នឹងល្បីល្បាញឮខ្ចរខ្ចាយទៅកាន់ទិសានុទិស"។

ស្រង់ពី ហិតោបទេស ទំព័រទី១៤-១៥ ភាគទី១

*******************************************************



[illegible]
មានការសើកដៃសំពះ ហោមរោគ ចាប់ដៃ បង្គួចនិងព្រះសង្ឃដើម.

# បទនីទ្រាំ

## វិជ្ជាជាទ្រព្យដ៏ឧត្តម

ហិតោបទេស

## ម៉ែ ឪ ជាអាចារ្យកូន

ម៉ែឪ ចិញ្ចឹមកូនឱ្យរស់ហើយមិនមែនអស់ប៉ុណ្ណឹងទេ មានភារៈត្រូវបង្រៀនកូនទៀតបានជាលោកពោលថា ម៉ែឪជាអាចារ្យដើមដំបូងបង្អស់មុនអាចារ្យទាំងពួងឯទៀត។ កាលកូនចេះនិយាយហើយ ម៉ែឪ បង្រៀនកូនឱ្យចេះភាសាជាតិរបស់ខ្លួន បង្រៀនឱ្យចេះហៅឪហៅម៉ែ ហៅយាយតា មាមីងបងប្អូន ហៅអ្វីៗនៅក្បែរខ្លួនដូចជាហៅគោក្របី ដីរ សេះ ផ្ទះ ដើមឈើ ថ្ងៃខែឆ្នាំ បង្រៀនឱ្យចេះដឹងថ្ងៃខែឆ្នាំកូន បង្រៀនហើយប្រាប់ឱ្យកូនថាត្រាប់តាម។ ការបង្រៀននេះច្រើនតែម្ដាយជាអ្នកបង្រៀន។ បើម៉ែបង្គាប់ឱ្យកូនថាតាម ហើយកូនថាត្រាប់បាន ម៉ែអរណាស់។ បើមានបងប្អូនមកលេងម៉ែប្រលងកូនល្បងមើលម៉ែសូមឱ្យបងប្អូនសួរថា នាងឈ្មោះអី កើតឆ្នាំអី ខែអី ថ្ងៃអី? បើកូនម៉ែឆ្លើយត្រូវ ម៉ែអរកខិបកខុបរីករាយសប្បាយចិត្តណាស់ហើយម៉ែអួតប្រាប់គេឯងថាកូនម៉ែមានប្រាជ្ញាណាស់។

ក្នុងការបង្រៀននេះ មិនមែនតែភាសាប៉ុណ្ណឹងទេម៉ែឪបង្រៀន

សណ្ដាប់ធ្នាប់របៀបរៀបរយ សុជីវធម៌ សីលធម៌ អរិយធម៌ ដូចជា បង្រៀនឱ្យលើកដៃសំពះយាយតា មាមីង បងប្អូនឬក្រាបសំពះភិក្ខុសាមណេរ បង្រៀនឱ្យចេះស៊ីឱ្យចេះដើរ ឱ្យដឹងទាបដឹងខ្ពស់ ឱ្យចេះស្គាល់ចាស់ទុំ ឱ្យចេះដឹងបន្តិចៗទៅដរាបដល់កូនធំបោះឡើងល្មមឱ្យចូលទៅរៀននៅសាលាឬទៅរៀននៅវត្ត។ ការទាំងអស់នេះម៉ែឪ ប្រើវិធីគ្រប់យ៉ាង បណ្ដោយតាមចិត្តកូនខ្លះ.បញ្ឆោរកូនខ្លះ.យកចិត្តកូនខ្លះ.ជួលខ្លះ.ឱ្យបំណាច់រង្វាន់ខ្លះ តំឡើងទឹកចិត្តខ្លះតាមតែគួរឱ្យតែកូនបានចេះ បានទៅជាមនុស្សល្អ មនុស្សប្រសើរមានចរិយាខ្ពង់ខ្ពស់។ ជួនកាលម៉ែឪ ប្រើវិធីក្ដៅខ្លះដែរ ប្រសិនបើមើលឃើញថា កូនមិនព្រមស្ដាប់បង្គាប់គឺប្រើវិធីកំញើញបង្ខិតបង្ខំដោយពាក្យសំដី តែការទាំងនេះគ្រាន់តែអាការៈខាងក្រៅទេ គឺស្ដីតែមាត់ តែចិត្តមិនទេ ចិត្តម៉ែឪ នៅតែមានមេត្តាដរាប។ អំពើបែបនេះក្នុងគម្ពីរដីកាលោកមិនពោលថាអំពើអាក្រក់ទេ ព្រោះម៉ែឪធ្វើដោយចិត្តមេត្តា។ ពេលណាម៉ែឪ ជ្រុលស្ដីថាឬវាយបន្តិចបន្តួចម្ដងម្កាល ចិត្តម៉ែឪ ឈឺផ្សា អន់ស្រពន់ទោរទន់ទៅរកកូន នឹកអាណិតអាសូរកូនខ្លោចចិត្ត ជួនកាលដល់ទៅស្រក់ទឹកភ្នែកផង។ សេចក្ដីនេះបញ្ជាក់ឱ្យឃើញថា កាយវាចាម៉ែឪ ម្យ៉ាង ចិត្តម៉ែឪ ម្យ៉ាង ការជេរស្ដីបន្ទោសវាយម៉ែឪ ផ្លាស់ប្ដូរបានតែចិត្តម៉ែឪ ផ្លាស់ប្ដូរឱ្យទៅចិត្តអាក្រក់បានចំពោះកូនមិនបានសោះឡើយ នៅតែជាចិត្តម៉ែឪមានមេត្តាស្រឡាញ់កូនដដែល



និយាយតាមបុរាណថា "ដេរទៅហៅមក" ។

ក្នុងការអប់រំកូន, ជីដូនជីតាមានការជួយរំលែកភារៈម៉ែដែរ មានឱកាសទំនេរជីដូនជីតានាំនិទានផ្សេងៗជាគតិលោក ជាគតិធម៌រឿងព្រេងនាយ,រឿងបច្ចុប្បន្ន,រឿងកំសាន្ត,រឿងត្លុកកំប្លែង រឿងដែលនាំឱ្យកើតគំនិតប្រាជ្ញា,មកឱ្យចៅស្តាប់ជាការកំសាន្តផង ជាប្រយោជន៍ឱ្យចៅយកតម្រាប់តាមផង ។ ពេលមានបុណ្យទានប្រចាំឆ្នាំនៅវត្ត ជីដូនជីតាម៉ែឪតែងនាំកូនទៅវត្ត ទៅដល់ហើយនាំឱ្យកូនទៅក្រាបសំពះព្រះសង្ឃព្រះពុទ្ធរូប ហើយស្តាប់ព្រះសង្ឃចំរើនព្រះបរិត្តពុទ្ធជ័យមង្គល, ស្តាប់ធម៌ទេសនារឿងបឋមសម្ពោធិ ទសជាតក៍ឬជាតកដទៃ ជារឿងដែលសំដែងពីចរិយាព្រះពុទ្ធជាម្ចាស់កាលទ្រង់បំពេញបារមីតាមប្រពៃណីនិយម ។ ជួនកាលម៉ែឪឬជីដូនជីតាដែលមានការចេះដឹងល្អពន្យល់កូនចៅថែមទៀត ដើម្បីឱ្យយល់សេចក្តីដោយមានបំណងចង់ឱ្យកូនចៅប្រព្រឹត្តតាមចរិយាព្រះពុទ្ធដែលជាហេតុនាំឱ្យធ្វើត្រាប់តាមនិងបានទៅជាអ្នកប្រសើរ បានជាភិក្ខុសាមណេរ ជាអរិយបុគ្គលក្នុងព្រះពុទ្ធសាសនាឬជាបុគ្គលម្នាក់ប្រសើរនៅនាលោកនេះឬបរលោក ។ បើឃើញថាកូនមានចរិយាមិនល្អ ម៉ែឪចំបែងចិត្តលំបាកស្ទើរប្រេះទ្រូងឬស្ទើរតែគ្រប់ជំហានជើង ម៉ែឪប្រើវិធីគ្រប់យ៉ាងក្តៅខ្ទះត្រជាក់ អង្វរករកូន ពឹងពាក់អ្នកចេះដឹងឱ្យជួយទូន្មានប្រៀនប្រដៅ បើឃើញថាមានចរិយាល្អហើយ ចេះគួរសមស្គាល់ចាស់ទុំ

ចេះឱនលំទោន ចេះស្គាល់ល្អអាក្រក់ ត្បៀវក្លាប្រសប់ប៉ិនចាំវ មានប្រាជ្ញា រៀនសូត្រ ឆាប់ចាំឆាប់ចេះដឹង មានកេរ្តិ៍ឈ្មោះប្រសើរ មានគេងងស្រឡាញ់រាប់អានច្រើនហើយម៉ែឪសប្បាយចិត្តណាស់។ បើម៉ែឪបានចេះដឹងថាបែបបទណាល្អ ម៉ែឪប្រៀនប្រដៅកូនភ្លាម ម៉ែឪប្រដៅថា កូនអើយ ! ចូរកូនធ្វើយ៉ាងនោះទើបបានជាកូនល្អ ។ សំដីម៉ែឪ នេះផ្អែមល្ហែមពិរោះពិសាណាស់ គួរជាទីគាប់ចិត្តកូនយ៉ាងក្រៃលែង ។ កាលបើឃើញថាកូនធំបៅហើយ. ល្មមទៅសាលារៀនបាន ម៉ែឪអង្វរករកូនឱ្យទៅរៀន និយាយឱ្យកូនទៅរៀន និយាយដោយពាក្យទន់ភ្លន់ថា កូន! កូនធំបៅហើយ ល្មមទៅសាលារៀនហើយ កូនធំហើយមិនចេះអក្សរ មិនចេះវិជ្ជា មិនប្រសើរទេណាំកូន! ចំណែកម៉ែមុនពេលកូនទៅសាលារៀន ម៉ែរៀបចំកាត់ខោអាវ រកគ្រឿងប្រដាប់ឱ្យកូនទៅរៀន ពេលដឹកដៃកូនចេញទៅ ម៉ែចំបែងចិត្តស្ទើរស្រក់ទឹកភ្នែក. មិនចង់ឱ្យកូនឃ្លាតពីទ្រូងទេ ដឹកដៃដើរបណ្តើរមាត់ម៉ែនិយាយបណ្តើរថា កូន! ទៅរៀនកុំខ្ជិល ប្រយ័ត្នកុំទាស់ ទែងនឹងគេ ខំរៀនឱ្យលោកគ្រូស្រឡាញ់ ឱ្យម៉ែសប្បាយចិត្ត មកផ្ទះវិញកុំអាល័យលេងតាមផ្លូវ មើលឆ្វេងស្តាំប្រយ័ត្នតាមផ្លូវខ្លាចក្រេងរទេះ.ឡាន.កង់ជាន់ប៉ះទង្គិច ។ ចេញផុតពីផ្ទះចិត្តម៉ែរឹតចំបែងខ្លាំងឡើងហាក់ដូចជាបែកសញ្ញែកជាពីរបី ជួនកាលកូនម៉ែមិនចង់ទៅរៀនយំយែកព្រោះខ្ជិល.ចូលចិត្តលេង ម៉ែពិបាកចិត្តស្ទើរប្រេះទ្រូង ។ កូនម៉ែចេញ

ទៅរៀនបាត់ហើយ បាត់មុខកូនព្រឹកល្ងាច ចិត្តម៉ែតាមទៅមើលមុខកូន នៅសាលារៀនរាល់វេលា ឃើញតែមុខកូននៅជាប់ក្នុងរង្វង់ភ្នែក។ ដល់ម៉ោងមកផ្ទះវិញ ម៉ែទន្ទឹងមើលផ្លូវកូន បើមិនទាន់ឃើញមកដល់ ចិត្តម៉ែខ្វល់ខ្វាយ អើតងើបមើលតែទៅមុខផ្ទះ ចេញមើលចូលមើល ហើយគិតមមៃថា ក្រែងកូនមានគ្រោះថ្នាក់លុះត្រាតែបានឃើញកូនមកដល់ផ្ទះហើយ ទើបម៉ែរីករាយសប្បាយចិត្ត មុខម៉ែញញឹមញញែមចៅរ៉ៅសួរទៅកូនថាៈ ម៉េចទៅកូន! លោកគ្រូស្រឡាញ់ឬទេ? បើកូនប្រាប់ថាថ្ងៃនេះលោកគ្រូបន្ទោសព្រោះកូនមិនសូវចាំមេរៀនម៉ែក្រៀមក្រំមុខតឹងទ្រូងហើយប្រដៅកូនបន្ថែមទៀតថា ខំរៀនទៅកូន! កុំឱ្យលោកគ្រូពិបាកចិត្ត រៀនឱ្យចេះឱ្យលោកគ្រូសរសើរកូនថា កូនជាកូនសិស្សល្អ ម៉ែក៏សប្បាយចិត្តផង បើកូនប្រាប់ថាថ្ងៃនេះកូនរៀនឈ្នះគេ លោកគ្រូសរសើរកូនឱ្យពិន្ទុច្រើន ម៉ែរីកមុខដូចផ្កាឈូក អរណាស់ហើយនិយាយថា ខំរៀនទៅកូនម៉ែ! ឱ្យម៉ែសប្បាយចិត្ត ហើយម៉ែរៀបចំបាយទឹកឱ្យកូនបរិភោគ ។ ពេលខ្លះម៉ែធ្វើនំនែកទុកឱ្យកូនខ្លាចក្រែងមកដល់ឃ្លានអាហារពេក ម៉ែមើលខោអាវបោកគក់ អ៊ុតបត់ទុកឱ្យកូន ម៉ែតែងគិតយ៉ាងនេះរាល់ពេលវេលា ។ ពេលយប់ម៉ែមើលកូនឱ្យរៀន ឮសូរមាត់កូនរៀន. ទន្ទេញ. ឃើញសរសេរ. ម៉ែសប្បាយចិត្ត ម៉ែបបោសអង្អែល.បោសមូសឱ្យកូន រៀនយូរពេកម៉ែប្រាប់ថា កូនយប់យូរហើយ! រៀបចំដេកទៅកុំនៅយប់ពេក ។ ម៉ែមើលថែទាំគ្រប់



ម៉ែធ្វើការនៅផ្ទះ៖ ឪពុកធ្វើការនៅស្រែ ដើម្បី
ផ្គត់ផ្គង់ជីវភាពក្រុមគ្រួសារ, កូនទៅ
រៀនឯសាលាដើម្បីរៀនវិជ្ជាទុកអនាគតផង.

ពេលវេលា បិទភ្លើងដេកហើយម៉ែទៅលបមើលទៀត ក្រែងមុងមិនជិតល្អ, ក្រែងដណ្តប់មិនល្អ, ម៉ែជួយដណ្តប់, ជួយរៀបចំដំណេកឱ្យល្អ ជូនកាលលបថើបកូនដោយបុត្រស្នេហា ។ ពេលព្រឹកព្រហាមព្នូសួរតែមាត់ម៉ែហាហៅកូន, កូនអើយកូន! ភ្ញីហើយងើបឡើងទៅលុបលាងមុខនឹងអាលញ៉ាំបបរ រៀបចំនឹងទៅសាលាឱ្យទាន់ពេលវេលា ម៉ែក្រ, ម៉ែខំបេះលុយកាក់ដាក់ហោប៉ៅទុកឱ្យកូន ខ្លាចក្រែងស្រេកទឹកឃ្លានចំណី គ្រាន់នឹងបានទិញញ៉ាំបណ្តោះអាសន្ន ទំរាំមកដល់ផ្ទះវិញ ហើយម៉ែតាមទៅមើលកូនទាល់តែចេញផុតពីផ្ទះទៅ ។ នេះជាកិច្ចវត្តម៉ែគ្រប់ពេលវេលា។ កូនម៉ែគ្រប់គ្នាបើបានគិតឃើញយ៉ាងនេះហើយ គួរតែក្រាបទៀបជើងម៉ែឪ,សំពះព្រះគុណម៉ែឪដែលមិនមានអ្វីមកផ្ទឹមឱ្យត្រឹមស្មើបានឡើយ ។

*******************************************************

"-បណ្ដាទ្រព្យទាំងពួង វិជ្ជា លោកពោលថាជាទ្រព្យដ៏ឧត្តម ព្រោះវិជ្ជា ចោរលួចយកមិនបានផង កាត់ថ្លៃមិនបានផង មិនវិចវិលអស់ទៅផង សព្វៗកាល"។

"-វិជ្ជាឃិតយោងជនដែលនៅថោកទាបឱ្យបានចូលទៅជិតព្រះនរបតី ដែលគេទៅជិតបានដោយកម្រ ឬអ្នកមានបុណ្យដ៏ក្រៃលែងជាងព្រះនរបតីទៅទៀត ដូចស្ទឹងដែលនៅក្នុងទីទាបតែងប្រមូលយកទឹកទៅកាន់សមុទ្រ"។

"-វិជ្ជានាំឱ្យមានវិន័យ វិន័យនាំឱ្យបានសេចក្ដីថ្លៃថ្នូរ សេចក្ដីថ្លៃថ្នូរនាំឱ្យបានទ្រព្យសម្បត្តិ ទ្រព្យសម្បត្តិនាំឱ្យបានធម៌ ធម៌ដឹកនាំឱ្យបានសេចក្ដីសុខ"។

ដកស្រង់ពី ហិតោបទេស ភាគ១ ទំព័រ១១-១២

*******************************************************

## បទនីទ្រាំមួយ

ទំពាំងស្នងឫស្សី

បូរាណសុភាសិត

ម៉ែឪ សង្គ្រោះកូន

កូនធំពេញរូបរាងហើយម៉ែឪ មិនទាន់ផុតរវល់ទេ នៅមានភារៈសង្គ្រោះទៀត ព្រោះកូនមិនទាន់មានស្លាបផុះក្រាស់ល្មមហើរខ្លួនឯងបាន។ ម៉ែឪ ទូន្មានប្រៀបប្រដៅ អប់រំសីលធម៌ចរិយា ដើម្បីឱ្យកូនបានពេញអង្គជាមនុស្ស មិនតែប៉ុណ្ណោះទេម៉ែឪ ចែកទ្រព្យសម្បត្តិឱ្យថែមទៀត ដើម្បីឱ្យបានជាដើមទុនកុំឱ្យក្រីក្រ ។

ចូរមើល ! ទ្រព្យសម្បត្តិដែលម៉ែឪ ខំប្រឹងប្រែងរកទាល់តែបែកញើសតាងទឹកបានមកទាំងប៉ុន្មាន ម៉ែឪ មិនហ៊ានស៊ីចាយខ្លួនឯងសប្បាយអស់ទេ លាក់លៀមសំចៃទុកខ្លះ ដើម្បីទំនុកបំរុងកូន ខ្លាចក្រែងកូនក្រីក្រមិនពេញមុខមាត់នឹងគេ ខ្លួនឯងស៊ូអត់ឃ្លានរងទុក្ខលំបាក ។ នេះទឹកចិត្តម៉ែឪ សង្គ្រោះកូន សុខចិត្តខ្លួនឯងអត់ឱ្យតែបានកូនស្រួល, ម៉ែឪ មិនគិតពីការនឿយហត់ទេ ដោយបានគិតថា "បើលំបាកឱ្យលំបាកត្រឹមតែម៉ែឪ ទៅចុះ កុំឱ្យលំបាកក្រីក្រនេះតាមទៅធ្លាក់ដល់កូនទៀត"។ ក្រៅពីម៉ែឪមាននរណាអាចបំពេញធម៌នេះបានឬទេ?


អនុវិទ្យាល័យ ទេពប្រណម្យ.

ក្នុងការសង្គ្រោះនេះ ម៉ែឪ ព្រួយបារម្ភជានិច្ច ឱ្យកូនទៅរៀនទៅ តែខ្លាចកូនមិនចេះមិនដឹង ទៅជាល្ងង់ខ្លៅមិនស្គាល់ល្អអាក្រក់ មិនបាន ទៅជាមនុស្សនឹងគេ ម៉ែឪ ណែនាំពន្យល់ប្រាប់ផ្លូវក្នុងជីវិតឱ្យកូនដើរទៅ ក្នុងនេះបានប្រកបដោយសុវត្ថិភាពទៀត ។ ម៉ែឪគិតថា បើកូនថោកទាប ខ្លួនក៏ថោកទាបដែរ ព្រោះពាក្យប្រវាទនៃលោកតែងនិយាយថា "ម៉ែឪវា អីចឹងបានជាកូនវាអីចឹងដែរ" ម្ល៉ោះហើយកេរ្តិ៍ឈ្មោះវង្សត្រកូលក៏ទៅជា ថោកទាប ខាតកម្លាំងពង្វៃ កម្លាំងចិញ្ចឹមឥតអំពើ. បើកូនខ្ពង់ខ្ពស់ ខ្លួនក៏ បានខ្ពង់ខ្ពស់. ក៏បានម៉ែឪ ជាអ្នកប្រសើរដែរ ព្រោះពាក្យប្រវាទនៃលោក តែងនិយាយថា "ពូជគេខ្ពង់ខ្ពស់" ម្ល៉ោះហើយកេរ្តិ៍ឈ្មោះវង្សត្រកូលក៏ អណ្តែតខ្ពង់ខ្ពស់ត្រឡុងត្រឡាយឡើង ។

មួយទៀតកាលកូនពេញកម្លោះក្រមុំ ចេះដឹងគួរសមហើយ គួរតែ ម៉ែឪ ស្រាលភារៈបន្តិច តែពុំមែនដូច្នោះទេ ម៉ែឪ ក៏នៅតែមិនអស់មិន ហើយ ចិត្តម៉ែឪ នៅតែរវាំងប្រយ័ត្នជាប្រក្រតីខ្លាចក្រែងកូនភ្លើតភ្លើនទៅ តាមកាមារម្មណ៍ ឬប្រព្រឹត្តធ្វើអបាយមុខណាមួយ ដែលជាហេតុធ្វើឱ្យ អាប់ឱ នកេរ្តិ៍ឈ្មោះបោះសម្លេងវង្សត្រកូល។ កាលបើឃើញកូនទៅណា ខុសកាលវេលា ទឹកមុខម៉ែឪ មិនស្រស់នៅមិនសុខ ធ្មេចភ្នែកមិនជិតទេ។ ម៉ែឪ ទ្រាំទ្រទុក្ខយ៉ាងនេះ អស់កាលយូរទាល់តែកូនមានគូស្រករ មានផ្ទះ

សំបែងជាឡាក់ឋានត្រឹមត្រូវ ហើយមានការចិញ្ចឹមជីវិតជាគ្រឿងប្រកាន់ដោយសុចរិតហើយ. ទើបម៉ែឪដេកនៅជាសុខតាំងចិត្តជាឧបេក្ខាបាន។ សេចក្ដីពិតរបស់ម៉ែឪ គិតក្នុងចិត្តជរាបថា "សូមឱ្យកូនជាមនុស្សល្អ កុំឱ្យទៅជាមនុស្សអាក្រក់ឡើយ" បើបែរជាមិនសមប្រាថ្នាខ្លួនទេ កូនទៅជាមនុស្សអាក្រក់ធ្វើចិត្តចោរចិត្តយក្ខចិត្តមារ "ម៉ែឪកើតទុក្ខគ្រប់ជំហានជើង" ទៅណាមិនពេញមុខនឹងគេទេ ។

កាលបើម៉ែឪ ឃើញកូនល្អសមតាមប្រាថ្នាខ្លួនហើយ គឺបានចេះបានដឹងគតិលោក គតិធម៌ ដម្កល់ខ្លួនទៅតាមធម៌មានឡាក់ឋានត្រឹមត្រូវ មានទ្រព្យសម្បត្តិ មានកេរ្តិ៍ឈ្មោះបោះសម្លេងប្រសើរជាត្រីមុខគេហើយ ឬបានបួសជាភិក្ខុសាមណេរ ក្នុងបវរពុទ្ធិសាសនា មានប្រាជ្ញាបាធីជាអ្នកប្រាជ្ញរាជបណ្ឌិត ម៉ែឪសប្បាយរីករាយក្រៃលែងភ្លេចនឿយហត់អស់ធ្មេចភ្នែកដេកនៅជាសុខដោយគិតឃើញថា "អាត្មាអញបានបំពេញធម៌ ជាម៉ែឪ បរិបូរណ៍ហើយ"។ និយាយមកដល់ត្រង់នេះ បើកូនគ្រប់រូបបានយល់ឃើញច្បាស់ថាគុណធម៌ដ៏ធ្ងន់នៃម៉ែឪ នេះ មិនអាចតបបានដោយថ្នូរយ៉ាងនេះបានហើយ គួរតែចូលទៅក្រាបសំពះទាបបាទាម៉ែឪរបស់ខ្លួន. ព្រោះម៉ែឪ មិនមែនបង្កើតត្រឹមតែសិរសាខ្លួនប៉ុណ្ណោះទេ ម៉ែឪ ប្រសូតិគុណសម្បត្តិគ្រប់ប្រការផង និងគុណធម៌ទាំងឡាយផងទុកឱ្យថែមទៀត ។

ខ្ញុំបាននិយាយមកហើយថា ការចិញ្ចឹមកូន ការអប់រំកូន ការសង្គ្រោះកូនជាភារៈធ្ងន់ហើយធ្ងន់ណាស់ លោកទុកភារៈសង្គ្រោះកូនជាភារៈសង្គ្រោះលោកតែម្តង ព្រោះលោកផែនទឹកផែនដីយើងនេះ តែងមានភារៈទាក់ទងនឹងមនុស្សលោក ។ រីឯលោកផែនទឹកផែនដីដែលនឹងតាំងនៅបាន ហើយចំរុងចំរើនបានឡើង បានសេចក្តីសុខក្សេមក្សាន្ត ឬដែលនឹងត្រូវវិនាសលាញទៅវិញ ហើយបានសេចក្តីទុក្ខលំបាកក៏ដោយសារមនុស្សលោក គឺកូននេះឯង គឺបើកូនល្អ កូនសម្មាទិដ្ឋិ មានគំនិតយល់ត្រូវតែងនឹងធ្វើការងារល្អប្រពៃ បានសេចក្តីថាមនុស្សល្អធ្វើបានតែអំពើល្អ ធ្វើអាក្រក់មិនកើត ធ្វើល្អយ៉ាងនេះហើយលោកនេះមុខជាលឿនទៅកាន់សេចក្តីចំរើនបានសុខសប្បាយក្សេមក្សាន្ត ព្រោះសេចក្តីចំរើនសុខក្សេមក្សាន្តកើតបានមកតែពីអំពើនៃលោក គឺកូនល្អ បើកូនអាក្រក់ កូនមិច្ឆាទិដ្ឋិ មានគំនិតយល់ខុស យល់ល្អថាអាក្រក់ យល់អាក្រក់ថាល្អ យល់លាមកថាជាផ្កា ហើយនឹងតែងធ្វើការងារអាក្រក់ បានសេចក្តីថាមនុស្សអាក្រក់ធ្វើបានតែអំពើអាក្រក់ ធ្វើល្អមិនកើត ធ្វើអាក្រក់យ៉ាងនេះហើយ លោកនេះនឹងធ្លាក់ទៅកាន់សេចក្តីវិនាសហិនហោច ហើយបានសេចក្តីទុក្ខលំបាកពុំខាន ព្រោះសេចក្តីវិនាសទុក្ខលំបាក កើតបានមកពីអំពើនៃលោក គឺកូនអាក្រក់ ។ លោកយើងនេះដែលបានចំរើនមកហើយបានសុខក្សេមក្សាន្តមកហើយ ពិតជាបានដោយអនុភាពម៉ែឪ ពីបុរាណ

ដែលបានសង្គ្រោះកូនដោយប្រពៃ យើងនឹងអាចពោលថា "លោករបស់ម៉ែឪ" ក៏សឹងបាន ។

ហេតុដូច្នេះហើយ ម៉ែឪ ត្រូវសង្គ្រោះកូនដោយធម៌ប្រពៃ ដោយខានពុំបាន ត្រូវពត់ ត្រូវហ្វឹកហ្វឺន ត្រូវទូន្មានប្រៀនប្រដៅ ត្រូវអប់រំកូនទាន់កូននៅតូចអាចធ្វើបាន ដើម្បីឱ្យកូនបាក់ផ្នត់គំនិតទៅខាងអំពើល្អ គឺឱ្យកូនដម្កល់ខ្លួនត្រូវក្នុងសទ្ធាសីល ចាគៈ ក្នុងសម្មាទិដ្ឋិ មានសម្មាទិដ្ឋិជាពន្លឺអុចទ្រោលបំភ្លឺមើលផ្លូវដើរទៅក្នុងលោកងងឹតនេះ ព្រោះលោកពោលថា "ដម្កល់ចិត្តត្រូវ ប្រសើរក្រៃលែងប្រសើរ ដម្កល់ចិត្តខុសអាក្រក់ក្រៃលែងអាក្រក់ម៉ែឪ ញាតិសន្តានជួយពុំបានទេ"។ កូនបែបនេះជាកូនប្រសើរ ជាកូនសប្បុរស យិតយោងម៉ែឪ ញាតិសន្តានឱ្យបានរួចចាកទុក្ខ ឱ្យបានខ្ពង់ខ្ពស់ ហើយធ្វើការនាំលោកនេះទៅកាន់សេចក្តីចំរើនសុខក្សេមក្សាន្ត ព្រោះបានទូន្មានខ្លួនដែលមានសន្តានចិត្តជាបុថុជ្ជនឱ្យទៅជាសន្តានចិត្តនៃព្រះអរិយបុគ្គលដែលមានឥន្ទ្រីយ៍ឈ្នះហើយមានខ្លួនឈ្នះហើយសមដូចពុទ្ធភាសិតថា "អរិយបុគ្គលធ្វើអំពើល្អបានដោយងាយ ធ្វើអំពើអាក្រក់បានដោយកម្រ ឯបុថុជ្ជនវិញធ្វើអំពើអាក្រក់បានដោយងាយធ្វើអំពើល្អបានដោយកម្រ"។ ការសង្គ្រោះកូនដោយធម៌ជាការងារលោកទាំងមូលមែនឬទេ? នេះជាប្រស្នាធំណាស់ គ្រប់ប្រទេសក្នុងលោកបានខំតស៊ូមកយូរអង្វែងឆ្នាំហើយរហូតមកដល់សព្វថ្ងៃនេះតែងបានលទ្ធផល

មិនទាន់សមប្រាថ្នាទេ តើយើងជាកូនរាល់គ្នាត្រូវប្រតិបត្តិចំពោះម៉ែឪយើងដូចម្ដេច?

ក្នុងពុទ្ធសាសនា ព្រះសម្មាសម្ពុទ្ធបានត្រាស់សង្គហធម៌ប្រាំប្រការ ៗ ទុកក្នុងសិង្គាលោវាទសូត្រថា ប្ដីត្រូវសង្គ្រោះប្រពន្ធ ប្រពន្ធត្រូវសង្គ្រោះប្ដី មាតាបិតាត្រូវសង្គ្រោះកូន កូនត្រូវសង្គ្រោះមាតាបិតា ។ល។ ចំពោះមាតាបិតាសង្គ្រោះកូនទ្រង់ត្រាស់ថា :

១. ហាមកូនកុំឱ្យធ្វើអំពើអាក្រក់

២. អប់រំកូនឱ្យតាំងក្នុងអំពើល្អ

៣. ញ៉ាំងកូនឱ្យសិក្សាវិជ្ជាដោយប្រពៃ

៤. រៀបចំកូនឱ្យមានស្វាមីភរិយាដ៏សមគួរតាមភាពនៃត្រកូល

៥. ចែកកេរ្ដិ៍មរតកឱ្យកូនក្នុងកាលគួរ ព្រមទាំងចែកចាយក្នុងពេលជានិច្ច ។

ចូរពិចារណាមើល! សង្គហធម៌ប្រាំប្រការនេះមានតម្លៃខ្ពង់ខ្ពស់ណាស់ មាតិកាមួយៗជាស្លោកគឺជាមេពាក្យ មានអត្ថជ្រាលជ្រៅទូលំទូលាយណាស់ អធិប្បាយមិនអស់ជើងទេ ហើយមិនមានលោកណាឬមេសាសនាណាមួយអាចប្រមូលយកការងារមាតាបិតាមកចងក្រងជាមាតិកាខ្លីៗ ហើយបានសេចក្ដីច្រើនយ៉ាងនេះឡើយ. មួយទៀតបើយើងចង់កសាងលោកនេះឱ្យមានអរិយធម៌ប្រសើរក៏យើងមិនដឹងជាទៅរកធម៌

ណាដទៃឱ្យមានតម្លៃប្រសើរនឹងសង្គហធម៌នេះបានដែរ បើយើងពិនិត្យមើលសង្គហធម៌ប្រាំប្រការនេះឱ្យល្អិតទៅទៀត. យើងឃើញថាធម៌បីប្រការខាងដើមមានន័យវិសេសវិសាលក្រៃពេក. ម៉ែឪដែលប្រាថ្នាឱ្យកូនបានល្អ ត្រូវអនុវត្តធម៌បីប្រការនេះដោយព្យាយាមធំមាំមួនណាស់ ត្រូវប្រើកម្លាំងកាយ កម្លាំងចិត្ត និងកម្លាំងទ្រព្យដ៏ធំ ទើបអាចសំរេចតាមសេចក្ដីប្រាថ្នាបាន។ បើម៉ែឪបានយកធម៌នេះទៅអនុវត្តចំពោះកូនគ្រប់គ្នាឱ្យបានពេញបរិបូរណ៍តាមពុទ្ធបំណងហើយ លោកនេះនឹងបានចំរើន បានសុខក្សេមក្សាន្តសមតាមប្រាថ្នាយើងពុំខានឡើយ តែមុខគួរស្តាយណាស់ យើងមានតែផ្លូវឥតមនុស្សដើរ មើលចុះ!

មាតិកាទីមួយថា "*ហាមកូនកុំឱ្យធ្វើអំពើអាក្រក់*" បានសេចក្ដីថាពត់ហ្វឹកហ្វឺន ទូន្មានប្រដៅអប់រំកូនឱ្យខ្លាចរអា ខ្មាស់អំពើអាក្រក់ អំពើថោកទាប អំពើខុសគន្លងធម៌គ្រប់យ៉ាង. ព្រោះអំពើអាក្រក់ទាំងអស់សុទ្ធតែធ្វើមនុស្សឱ្យថោកទាបទៅជាសភាពតិរច្ឆាន ។ តើវិធីអស់នេះយើងត្រូវធ្វើក្បួនខ្នាតអនុវត្តបែបណាឱ្យអស់ជើង ព្រោះត្រូវទូន្មានកាយ វាចា ចិត្ត ឱ្យមានសីលធម៌ខ្ពង់ខ្ពស់ ឱ្យមានចរិយាប្រសើរ គឺឱ្យបានពេញអង្គជាមនុស្ស?

មាតិកាទីពីរថា "*អប់រំកូនឱ្យតាំងនៅក្នុងសេចក្ដីល្អ*" ពោលគឺឱ្យកូនតាំងខ្លួននៅក្នុងធម៌ ឱ្យមានមនុស្សធម៌ ព្រោះមានតែធម៌ទេដែលអាច

ធ្វើមនុស្សជាតិឱ្យប្លែកពីសត្វតិរិច្ឆាន លោកពោលទុកថា"ស៊ី ដេក ភ័យ បរិភោគ កាមធម៌៤ប្រការនេះ មនុស្សនិងសត្វមានដូចគ្នា មិនប្លែកគ្នាទេ ចុះអ្វីដែលអាចធ្វើមនុស្សឱ្យប្លែកពីសត្វបាន? ថាមានតែព្រះធម៌ទេទើប ធ្វើឱ្យមនុស្សប្លែកពីសត្វបាន ថាបើមិនដូច្នោះទេ មនុស្សនិងសត្វដូចគ្នា"។ កិច្ចការអស់នេះក៏ត្រូវមានក្បួនចរិយាសាស្ត្រមួយធំសម្បើមណាស់ដែរ ទើបកូនមានសតិសម្បជញ្ញៈគ្រប់គ្រងល្មមត្រង់វង្សតាំងនៅក្នុងធម៌ល្អបាន ព្រោះមនុស្សមិនងាយស្គាល់តម្លៃសេចក្ដីល្អគឺព្រះធម៌ពិតមែនបានដោយ ងាយៗបានទេ។

មាតិកាទីបីថា *"ញ៉ាំងកូនឱ្យសិក្សាវិជ្ជាដោយប្រពៃ"* បទនេះធំ ក្រៃលែងធំទៅទៀត ព្រោះជាក្រសួងសិក្សាធិការមួយទៅហើយ។វិជ្ជាមាន ច្រើនណាស់ក្នុងលោកនេះរៀនមិនអស់ទេ, ហើយមិនមានទីបំផុតផង តែត្រូវតែរៀនទឹងខានពុំបាន បានប៉ុន្មានយកប៉ុណ្ណោះ,ឱ្យតែបានឡើង ឈ្មោះថា "មានការសិក្សាបរិបូរណ៍ហើយ"កុំឱ្យគេបន្ទោសថា"ឥតការ សិក្សា"ថោកទាបពេកណាស់ ព្រោះការសិក្សាវិជ្ជានាំយើងឱ្យមានតម្លៃ ខ្ពង់ខ្ពស់សមតាមមនុស្សធម៌។

ម៉ែឪ ទាំងឡាយដែលបានបង្កើតកូនមកហើយបីបាច់ថែរក្សា ចិញ្ចឹម សង្គ្រោះទូន្មានប្រៀនប្រដៅអប់រំកូន ដោយព្យាយាមមាំមួនអស់កម្លាំង នឿយហត់ច្រើនឆ្នាំមិនចង់បានអ្វីដទៃទេ ចង់បានតែកូនល្អ បើបានកូនល្អ

សមតាមប្រាថ្នារបស់ខ្លួនហើយតែងរីករាយសប្បាយចិត្តក្រៃលែងនឹកសង្ឃឹមថាបានកូននេះហើយជាទំពាំងស្នងឫស្សីថែរក្សាចិញ្ចឹមខ្លួនវិញជាទីពឹងពំនាក់ក្នុងពេលដែលខ្លួនចាស់ជរាទៅ បានជាព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ទុកក្នុងបុត្តសូត្រអង្គុត្តរនិកាយបញ្ចកនិបាតថាៈ បណ្ឌិត(មាតាបិតា)កាលឃើញការគួរទាំងឡាយ៥ប្រការ,ទើបប្រាថ្នាកូនគឺៈ

១. កូនដែលខ្លួនចិញ្ចឹមហើយ នឹងចិញ្ចឹមខ្លួនវិញ

២. កូនដែលខ្លួនចិញ្ចឹមហើយ នឹងធ្វើការជួសខ្លួនវិញ

៣. កូនដែលខ្លួនចិញ្ចឹមហើយ នឹងរក្សាវង្សត្រកូលឱ្យឋិតថេរចីរកាលតទៅ

៤. កូនដែលខ្លួនចិញ្ចឹមហើយនឹងរក្សាមរតករបស់ខ្លួនទុកឱ្យគង់វង់

៥. ខ្លួនស្លាប់ទៅហើយ បានកូននឹងធ្វើទក្ខិណានុប្បទានឱ្យ។

បណ្ឌិត(មាតាបិតា) កាលឃើញការគួរទាំងនេះហើយបានជាប្រាថ្នាកូនព្រោះហេតុនោះកូនដែលមានសន្តានសប្បុរស,ជាសន្តបុគ្គល,ជាកតញ្ញូ,ជាកតវេទី កាលរលឹកឃើញនូវឧបការគុណទាំងនេះ ដែលមាតាបិតាបានធ្វើដល់ខ្លួនកាលពីមុនហើយ :

- គប្បីចិញ្ចឹមមាតាបិតា

- គប្បីធ្វើការផ្ចូសមាតាបិតាដែលជាបុព្វការីរបស់ខ្លួនវិញតាមសមគួរដល់ការ
- គប្បីលុះក្នុងឱវាទនៃមាតាបិតា
- គប្បីថែរក្សាវង្សត្រកូលឱ្យបានឋិតថេរកុំឱ្យវិនាស
- គប្បីប្រកបដោយសទ្ធា
- គប្បីប្រកបដោយសីល

កូនប្រសើរបែបនេះ ទើបបណ្ឌិតលោកសរសើរ។

គេបានសង្កេតឃើញថាសត្វតិរច្ឆាន វាមិនចេះស្គាល់មេបាវា វាមិនចេះធ្វើបុណ្យឧទ្ទិសកុសលជូនមេបាវាទេ មេបាវាក៏មិនចេះស្គាល់កូនវាដែរ។ បើម៉ែឪ មិនស្គាល់កូន មិនរវល់នឹងកូន ឯកូនក៏មិនស្គាល់ម៉ែឪ មិនរវល់នឹងម៉ែឪ វិញដែរមានអ្វីអាក្រក់ជាងនេះទៅទៀតដែរ? ហើយលោកនេះនឹងទៅជាអ្វី?ក្នុងលោកនេះមានអ្វីដទៃថោកទាបជាងម៉ែឪ មិនស្គាល់កូន,ពុំនោះកូនមិនស្គាល់ម៉ែឪ នេះទៀតឬទេ?បើម៉ែឪ ស្គាល់កូន,រក្សាកូនដោយធម៌ឯកូនក៏ចេះស្គាល់ម៉ែឪ ហើយរក្សាម៉ែឪ ដោយធម៌វិញដែរ ក្នុងលោកនេះមានអ្វីដទៃប្រសើរជាងទៀតឬទេ?

កូនទាំងឡាយ! ម៉ែឪ ចិញ្ចឹមយើងហើយដោយទឹក ' ដោយអាហារភោជន ដោយគ្រឿងឧបករណ៍ផ្សេងៗដោយការឧ ្ហម្ភឱ្យរៀនចំណេះវិជ្ជា។ ចូរមើលរាងកាយយើងគ្រប់គ្នា!បានមកពីណា? នេះគឺជា

សាច់ឈាមជាញើសម៉ែឪទាំងអស់។ ពេលនេះជាភារៈយើងជាកូនគ្រប់គ្នាត្រូវធ្វើតបវិញ។

ព្រះដ៏មានបុណ្យបានត្រាស់ទុកក្នុងសព្រហ្មកសូត្រសោណនន្ទជាតកថា"ព្រោះហេតុនោះកូវ,កូនជាបណ្ឌិត គប្បីនមស្ការ,គប្បីធ្វើសក្ការៈ គប្បីចិញ្ចឹមមាតាបិតាដោយបាយទឹកនំចំណី,ដោយភេសជ្ជៈផ្សេងៗ ដោយគ្រឿងស្លៀកពាក់គ្រប់យ៉ាង,ដោយទីដេកទីអាស្រ័យនៅស្រួលគ្រប់ប្រការ គប្បីថែរក្សាព្យាបាលរោគាព្យាធិមាតាបិតាដោយថ្នាំកែរោគ គប្បីប្រោះព្រំមាតាបិតា លាបប្រេងលាបម្សៅការពារកុំឱ្យមានក្លិនអសោចដោយគ្រឿងក្រអូបផ្សេងៗ,គប្បីស្រង់ទឹកមាតាបិតាដោយទឹកក្តៅ,ទឹកត្រជាក់ព្រមទាំងដុះជម្រុះក្អែលមន្ទិលសៅហ្មង គប្បីគក់ច្របាច់ស្ពឹទឹកក្តៅរូតសរសៃរឱ្យខ្យល់ដើរស្រួល ដើម្បីជាផ ាសុកដល់មាតាបិតា"។

កូនគ្រប់គ្នា, បើបានបំពេញករណីកិច្ចរបស់ខ្លួនទៅតាមធម៌ដូចបានពោលមកនេះពេញបរិបូរណ៌ហើយទើបឈ្មោះថា "កូនចេះស្គាល់ម៉ែឪ ចេះស្រឡាញ់ម៉ែឪ ចេះគោរពម៉ែឪ " ទេវតានឹងរក្សាឱ្យបានសេចក្ដីសុខក្សេមក្សាន្ត ដូចពុទ្ធភាសិតដែលប្រទានឱវាទចំពោះអនាថបណ្ឌិតសេដ្ឋីក្នុងអាទិយសូត្រគម្ពីរអង្គុត្តនិកាយបញ្ចកនិបាតថា:"នរជនជាបណ្ឌិតនៅគ្រប់គ្រងផ្ទះ បើបានរំលឹកឃើញនូវឧបការគុណនៃមាតាបិតាទាំងនេះ បានស្ថិតនៅក្នុងអរិយធម៌គឺសីលប្រាំបើមិនទាន់ស្លាប់នៅក្នុងលោកនេះ នឹង

មានមនុស្ស,ទេពតាសរសើរ បើចែកឋានទៅហើយនឹងបានក្ដីរីករាយសប្បាយជាភិយ្យោភាពក្នុងបរលោកថែមទៀត"។

ដូច្នេះ, កូនទាំងឡាយ! ចូរបំពេញធម៌ទាំងនេះកុំបីខាន ដោយគិតថា " **នេះជាបុញ្ញក្ខេត្តរបស់អាត្មាអញរាល់ពេលវេលា** " ៕

0002589
ANGKOR THOM BOOKSHOP
$ 0.50